01241253

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

D257/1/8

តាមនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ២១)**

| | | |
|---|---|---|
| **ចំពោះមុខ:** | ចៅក្រម ប្រាក់ គឹមសាន | ប្រធាន |
| | ចៅក្រម Olivier BEAUVALLET | |
| | ចៅក្រម ន៉ីយ ថុល | |
| | ចៅក្រម Kang Jin BAIK | |
| | ចៅក្រម ហួត វុទ្ធី | |
| កាលបរិច្ឆេទ: | ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦ | |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 12 / 2016
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

## សេចក្តីពិចារណាលើសំណើរបស់ [redacted] សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាព កិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍**

មុំ លុដ្ឋ
Richard ROGERS
Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Linda BEHNKE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Emmanuel JACOMY
Beini YE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើរបស់ [redacted] សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេត ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" ដែល បានដាក់នៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៤ ("សំណើ")[1]។

## I. សេចក្តីផ្តើម

1. សំណើនេះត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បញ្ជូនទៅអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧៦(៣) នៃវិធានផ្ទៃក្នុង ("ដីកាសម្រេចបញ្ជូនសំណុំរឿង")[2]។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")[3] ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយចោទប្រកាន់អំពីការជាប់ពាក់ព័ន្ធរបស់ [redacted] (*ហៅ* "[redacted] និង [redacted]") នៅក្នុងអំពើឧក្រិដ្ឋ ដែលសំដៅដល់ ក្នុងចំណោមបទចោទផ្សេងៗទៀត បទចោទអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

3. នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") នូវ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ

---

[1] សំណើរបស់ [redacted] សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេត ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ A259។

[2] ដីកាសម្រេចរួមលើសំណើសុំមោឃភាពរបស់ [redacted] តាមវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D257 កថាខណ្ឌ ៤១-៤៣ ("ដីកាសម្រេចបញ្ជូនសំណុំរឿង")។ *សូមមើលផងដែរ* លិខិតពីក្រឡាបញ្ជីរបស់ ក.ស.ច.ស ផ្ញើជូនមន្ត្រីគ្រប់គ្រងសំណុំរឿង ស្តីអំពីការបញ្ជូនសំណៅថតចម្លងនៃសំណុំរឿង ០០៤ ទៅ អង្គបុរេជំនុំជម្រះ អនុលោមតាមសំណុំរឿង ០០៤-D257 ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ D257/1។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1 កថាខណ្ឌ ១១៧(គ)។ *សូមមើលផងដែរ* សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ ដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរលើកទី៣ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC CETC

ឬឃេនឌ័រ" ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម")[4] ជាសម្ងាត់ និងបាន ចេញ សេចក្តីថ្លែងការណ៍មួយដោយជូនដំណឹងដល់សាធារណជនអំពីការដាក់ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយបញ្ជាក់ថា "ព័ត៌មានបឋមដែលយើងមាននាពេលនេះបញ្ជាក់ថា អាពាហ៍ពិពាហ៍ដោយបង្ខំ [...] ត្រូវបានប្រព្រឹត្តឡើងដោយកម្មាភិបាលខ្មែរក្រហម និងបាន កើតឡើងនៅតាមតំបន់នានាដោយមានជនសង្ស័យដែលមានឈ្មោះនៅក្នុងសំណុំរឿង ០០៤ គឺជាអ្នកកាន់មុខនាទីជាអ្នកបញ្ជា ឬផ្នែកនយោបាយដ៏មានឥទ្ធិពល", ដែល "ដីកាសន្និដ្ឋានបញ្ជូន រឿងឱ្យស៊ើបសួរបន្ថែមផ្អែកទៅលើភស្តុតាងថ្មីដែលជាឯកសារដែលអាចរកបាន ចាប់តាំងពីពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៤ មក", សហព្រះរាជអាជ្ញាអន្តរជាតិ "*ជឿជាក់*ថា ការចោទប្រកាន់លើអង្គហេតុនានាដែលមាននៅក្នុងភស្តុតាងថ្មីនេះ គឺជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលរួមមាន [....] អំពើអមនុស្សធម៌ផ្សេងៗទៀត", សហព្រះ រាជអាជ្ញាអន្តរជាតិ "បានស្នើឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេតបន្តស៊ើបសួរទៅលើ ឧក្រិដ្ឋកម្មទាំងនេះបន្ថែមទៀត និងការទាក់ទងណាមួយទៅនឹងជនសង្ស័យដូចដែលមានឈ្មោះ ទាំងនោះ" និងចុងក្រោយបញ្ជាក់ថា "ជាសំខាន់គឺត្រូវជៀសវាងការធ្វើសេចក្តីសន្និដ្ឋានណាមួយ រហូតទាល់តែកិច្ចស៊ើបសួរបានចប់សព្វគ្រប់សិន"[5]។

4. នៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៤ សហមេធាវីរបស់ [redacted] បានដាក់សំណើនេះ។

5. នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥ [redacted] បានចូលរួមក្នុងសវនាការបង្ហាញខ្លួនលើកដំបូង ហើយ ស.ច.ស.អ បានចោទប្រកាន់គាត់ ក្នុងចំណោមបទល្មើសផ្សេងទៀតអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[6]។ ក្រោយមកទៀត នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ ស.ច.ស.អ បានចេញដីកាសម្រេចបញ្ជូនសំណុំរឿង ដោយមានការ "ជឿជាក់ថា មេធាវីការពារក្តី តាម រយៈ

---

[4] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាឃេនឌ័រ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D191 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម")។

[5] សហព្រះរាជអាជ្ញាអន្តរជាតិ សេចក្តីប្រកាសព័ត៌មាន៖ សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ Nicholas Koumjian ស្តីអំពី ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ http://www.eccc.gov.kh/sites/default/files/media/OCP%20Press%20Release%2024%20Apr%2014%20KHM.pdf (សេចក្តីបញ្ជាក់បន្ថែម)។

[6] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D242។

01241256



សំណើសុំមោឃភាពពាក់ព័ន្ធនឹងការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំ បានលើកឡើងពី "ករណីអាចជំទាស់តវ៉ាបាន" ដែលតម្រូវឱ្យបញ្ជូនសំណើនេះទៅអង្គបុរេជំនុំជម្រះ"[7]។

6. នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំការអនុញ្ញាតដាក់ចម្លើយតបរបស់គាត់ទៅនឹងសំណើសុំមោឃភាពពាក់ព័ន្ធនឹងការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំ តែភាសាអង់គ្លេសជាមុនសិន ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ[8]។

7. ដីកាសម្រេចបញ្ជូនសំណុំរឿង និងសំណៅថតចម្លងនៃសំណុំរឿង ០០៤ ត្រូវបានបញ្ជូនទៅអង្គបុរេជំនុំជម្រះ នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥[9]។

8. នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិ បានផ្ញើសារអេឡិចត្រូនិក ទៅកាន់មន្ត្រីច្បាប់របស់អង្គជំនុំជម្រះ ដោយស្នើសុំសេចក្ដីណែនាំទាក់ទិននឹងនីតិវិធីក្នុងការដាក់ចម្លើយតបទៅនឹង សំណើនេះ[10] ហើយនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ បានដាក់ចម្លើយតបមួយទៅនឹងសំណើនេះក្នុងទម្រង់ជាឯកសារអេឡិចត្រូនិក។

9. នៅថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១៥ មន្ត្រីទទួលបន្ទុកសំណុំរឿងបានជូនដំណឹងដល់ភាគីអំពី "សេចក្ដីណែនាំរបស់អង្គបុរេជំនុំជម្រះដល់ភាគី តាមរយៈសារអេឡិចត្រូនិក" ("សេចក្ដីណែនាំរបស់ អ.ប.ជ ថ្ងៃទី ៣ ខែ កញ្ញា") ដោយបានណែនាំឱ្យសហមេធាវីរបស់ [redacted] ដាក់ពាក្យសុំទៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងរយៈពេល ១០ថ្ងៃ ដែលចាប់ពីពេលនោះទៅ "កិច្ចដំណើរការនីតិវិធីលើពាក្យសុំ ត្រូវស្ថិតនៅក្រោមបញ្ញត្តិទូទៅនៃវិធាន ៧៧ នៃវិធានផ្ទៃក្នុង"[11]។

---

[7] ដីកាសម្រេចរួមលើសំណើសុំមោឃភាពរបស់ [redacted] តាមវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារ D257 កថាខណ្ឌ ៣០។

[8] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការអនុញ្ញាតដាក់សំណៅបកប្រែចម្លើយតបតាមក្រោយ ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ D257/1/3.3។

[9] ឯកសារ D257/1។

[10] សារអេឡិចត្រូនិក កម្មវត្ថុ កាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់ចម្លើយតបទៅនឹងសំណើរបស់ [redacted] សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាព ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ D257/1/3.4។

[11] សារអេឡិចត្រូនិកពីមន្ត្រីគ្រប់គ្រងសំណុំរឿង ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១៥ សេចក្ដីណែនាំរបស់អង្គបុរេជំនុំជម្រះដល់ភាគីតាមរយៈ សារអេឡិចត្រូនិក ថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០១៥ ឧបសម្ព័ន្ធ៦ ភ្ជាប់ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

10. នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ សហមេធាវីរបស់ [redacted] បានដាក់ការឆ្លើយតបរបស់ខ្លួនទៅនឹងសេចក្តីណែនាំរបស់ អ.ប.ជ ថ្ងៃទី ៣ ខែ កញ្ញា ដោយបានអះអាងថា ចម្លើយតបណាមួយទៅនឹងសំណើ ដែលបានដាក់នៅពេលនេះ គឺពុំបានដាក់ទៅតាមពេលវេលាដែលបានកំណត់ទេ ដូច្នេះអង្គជំនុំជម្រះត្រូវតែពិចារណាតែទៅលើចំណុចករណីដែលបានលើកឡើងនៅក្នុងសំណើបានហើយ ("ការឆ្លើយតបរបស់ [redacted] ទៅនឹងសេចក្តីណែនាំរបស់ អ.ប.ជ")[12]។

11. នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ចម្លើយតបរបស់គាត់ទៅនឹងសំណើរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការឆ្លើយតបរបស់គាត់ទៅនឹងសារអេឡិចត្រូនិករបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១៥ ("ចម្លើយតបរបស់ ស.ព.អ")[13]។

12. នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សំណើមួយ ជាភាសាអង់គ្លេសប៉ុណ្ណោះ សុំពន្យាររយៈពេលកំណត់ និងដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើតែមួយភាសាជាមុនសិន[14]។ សំណៅបកប្រែជាភាសាខ្មែរនៃសំណើនេះ ត្រូវបានជូនដំណឹងនៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥។ នៅថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៥ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់តែជាភាសាអង់គ្លេសប៉ុណ្ណោះនូវចម្លើយតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការឆ្លើយតបរបស់គាត់ទៅនឹងសារអេឡិចត្រូ

---

ទៅនឹងសំណើរបស់ [redacted] សុំឲ្យធ្វើមោឃភាពកិច្ចស៊ើបអង្កេត ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ និងការឆ្លើយតបរបស់គាត់ចំពោះសារអេឡិចត្រូនិករបស់អង្គបុរេជំនុំជម្រះ ខែ កញ្ញា ឆ្នាំ ២០១៥ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D257/1/3.7 ("សេចក្តីណែនាំរបស់ អ.ប.ជ ថ្ងៃទី ០៣ ខែ កញ្ញា")។

[12] ការឆ្លើយតបចំពោះសារអេឡិចត្រូនិករបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១៥ ទាក់ទងនឹង "សំណើរបស់ [redacted] សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេត ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ" (A259) ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D257/1/1។

[13] ឯកសារ D257/1/3។

[14] សំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យាររយៈពេលកំណត់ និងដាក់សំណើសុំនេះតែមួយភាសាជាមុនសិន ដើម្បីឆ្លើយតបទៅនឹងសំណើរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបអង្កេតទាំងអស់ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D257/1/2។

និករបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១៥ ("ចម្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី")[15]។ ចម្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានជូនដំណឹងតែជាភាសាអង់គ្លេសប៉ុណ្ណោះ នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៥។ សំណៅបកប្រែជាភាសាខ្មែរនៃចម្លើយតបនេះ ទទួលបាន នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥។ នៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៥ អង្គបុរេជំនុំជម្រះបាន ចេញសេចក្ដីជូនដំណឹងមួយ អនុលោមតាមវិធាន ៧៧(៣)(គ) នៃវិធានផ្ទៃក្នុង អំពីសេចក្ដីសម្រេច បន្តដំណើរការនីតិវិធី ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ប៉ុណ្ណោះ។ ពុំមានការដាក់ការឆ្លើយតបជាលាយលក្ខណ៍អក្សរនៅក្នុងកាលបរិច្ឆេទដែលបាន កំណត់ឡើយ។

13. នៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១៥ អ៊ឹម ចែម បានដាក់សំណើមួយសុំអនុញ្ញាតដាក់សារណាគាំទ្រ សំណើរបស់ [redacted] ("សំណើ និងសារណារបស់ [redacted]")[16]។ នៅថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំការអនុញ្ញាតដាក់ចម្លើយតបរបស់គាត់ទៅ នឹងសំណើ និងសារណារបស់ [redacted] តែមួយភាសាជាមុនសិន[17]។ នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់តែជាភាសាអង់គ្លេសប៉ុណ្ណោះ នូវចម្លើយតបរបស់ គាត់ទៅនឹងសំណើ និងសារណារបស់ [redacted] ដែលសំណៅជាភាសា ខ្មែរ ត្រូវបានដាក់ នៅ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ ("ចម្លើយតបរបស់ ស.ព.អ ទៅនឹង [redacted]")[18]។ ចម្លើយតប របស់ ស.ព.អ ទៅនឹង [redacted] ត្រូវបានជូនដំណឹងនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥។ មេធាវី តំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនបានដាក់ចម្លើយតបណាមួយ ទៅនឹងសំណើ របស់ [redacted]

---

[15] ចម្លើយតបរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់ [redacted] សុំឱ្យធ្វើមោឃភាពកិច្ចស៊ើប អង្កេតពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ និងការឆ្លើយតបរបស់គាត់ទៅនឹងសារអេឡិចត្រូនិករបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១៥ ថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D257/1/5។

[16] សំណើរបស់អ្នកស្រី [redacted] សុំអនុញ្ញាតដាក់សារណាគាំទ្រសំណើរបស់ [redacted] ដែលស្នើសុំឱ្យធ្វើមោឃភាពកិច្ចស៊ើប អង្កេត ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ យោងតាមសារអេឡិចត្រូនិករបស់អង្គបុរេជំនុំជម្រះ ធ្វើនៅថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១៥ ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D257/1/4។

[17] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការអនុញ្ញាតដាក់សំណៅបកប្រែនៃចម្លើយតបជាបន្តបន្ទាប់ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D257/1/6។

[18] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបអង្កេតលើអាពាហ៍ ពិពាហ៍ដោយបង្ខំ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ D257/1/7។

នៅក្នុងកាលបរិច្ឆេទដែលបានកំណត់នោះឡើយ។ សហមេធាវី របស់ [redacted] មិនបានដាក់ការឆ្លើយតប ណាមួយនៅក្នុងកាលបរិច្ឆេទដែលបាន កំណត់ ឡើយ។

14. នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ស.ច.ស.អ បានចោទប្រកាន់ [redacted] ក្នុងចំណោមបទល្មើសផ្សេងទៀត អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា អំពើអមនុស្សធម៌ផ្សេងៗទៀត រួមទាំងអាពាហ៍ពិពាហ៍ដោយបង្ខំ[19]។

## III. បញ្ហាបឋម

15. ជាដំបូង អង្គបុរេជំនុំជម្រះត្រូវដោះស្រាយសំណើរបស់ភាគីដែលលើកឡើងនូវបញ្ហាផ្នែកនីតិវិធីបឋមនៅក្នុងការឆ្លើយតបទៅនឹងសេចក្ដីណែនាំរបស់ អ.ប.ជ ថ្ងៃទី ៣ ខែ កញ្ញា ថា "កិច្ចដំណើរ ការនីតិវិធីលើពាក្យសុំ ត្រូវស្ថិតនៅក្រោមបញ្ញត្តិទូទៅនៃវិធាន ៧៧ នៃវិធានផ្ទៃក្នុង"[20]ដែលអនុញ្ញាតឱ្យភាគីនានាដាក់ចម្លើយតបទៅនឹងសំណើ។ [redacted] បានឆ្លើយតបថា ចម្លើយតបណាមួយទៅនឹងសំណើ ដែលបានដាក់នៅពេលនេះ គឺពុំបានដាក់ទៅតាមពេលវេលាដែលបានកំណត់ទេ[21]។ [redacted] បានស្នើសុំការអនុញ្ញាតដាក់សារណាដើម្បីគាំទ្រសំណើរបស់ [redacted][22]។

### III-1 តើចម្លើយតបទៅនឹងសំណើ ពុំបានដាក់ទៅតាមពេលវេលាដែលបានកំណត់ ឬយ៉ាងណា

16. [redacted] ជំទាស់នៅក្នុងការឆ្លើយតបរបស់គាត់ទៅនឹងសេចក្ដីណែនាំរបស់ អ.ប.ជ ថា ចម្លើយតបណាមួយទៅនឹងសំណើ ដែលបានដាក់នៅពេលនេះ គឺពុំបានដាក់ទៅតាមពេលវេលាដែលបានកំណត់ទេ ដូច្នេះ អង្គជំនុំបុរេជម្រះត្រូវតែពិចារណាតែទៅលើទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងសំណើបានហើយ[23]។ ទឡ្ហីករណ៍របស់ [redacted] នេះ ផ្អែកទៅលើមូលដ្ឋានចំនួនបួន ពោលគឺ៖ ១) ភាគីដទៃទៀតពុំបានធ្វើការឆ្លើយតបទៅនឹងសំណើនេះឡើយ នៅពេលដែលសំណើនេះត្រូវបាន

---

[19] កំណត់ហេតុនៃការបង្ហាញខ្លួនម្ដងទៀត ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ D303។

[20] សេចក្ដីណែនាំរបស់ អ.ប.ជ ថ្ងៃទី ៣ ខែ កញ្ញា កថាខណ្ឌ ៣។

[21] ការឆ្លើយតបរបស់ [redacted] ទៅនឹងសេចក្ដីណែនាំរបស់ អ.ប.ជ កថាខណ្ឌ ៤, ២៦។

[22] សំណើ និងសារណារបស់ [redacted] កថាខណ្ឌ១-៣។

[23] ការឆ្លើយតបរបស់ [redacted] ទៅនឹងសេចក្ដីណែនាំរបស់ អ.ប.ជ កថាខណ្ឌ ១-៤, ២៦-២៧។

ដាក់កាលពីដំបូងនៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤[24], ២) ភាគីដទៃទៀតពុំ បានធ្វើការឆ្លើយតបទៅនឹងសំណើនេះទេ នៅពេលដែល [redacted] ត្រូវបានចោទប្រកាន់ជា ផ្លូវការ (នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥)[25], ៣) ភាគីដទៃទៀតក៏ពុំបានប្ដឹងឧទ្ធរណ៍ ចំពោះដីកាសម្រេចរបស់ ក.ស.ច.ស ដែលបានបញ្ជូនសំណើទៅ អ.ប.ជ នោះឡើយ[26] និង ៤) រហូតមកដល់ពេលនេះ ពុំមានដីការបស់តុលាការ អនុលោមតាមវិធាន ៣៩(៤) នៃវិធាន ផ្ទៃក្នុង ដើម្បីពន្យារកាលបរិច្ឆេទក្នុងការឆ្លើយតបទៅនឹងសំណើនេះឡើយ[27]។ ស.ព.អ ឆ្លើយ តបថា ចម្លើយតបរបស់ខ្លួនទៅនឹងសំណើនេះត្រូវបានដាក់ អនុលោមតាមកាលបរិច្ឆេទ ដែល បានកំណត់នៅក្នុងសេចក្ដីណែនាំរបស់ អ.ប.ជ ថ្ងៃទី ៣ ខែ កញ្ញា[28]។ ដើមបណ្ដឹងរដ្ឋប្បវេណី ឆ្លើយតបថា នៅពេល [redacted] ដាក់សំណើកាលពីដំបូងនៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ភាគី ដទៃទៀតពុំមានកាតព្វកិច្ចត្រូវឆ្លើយតបទៅនឹងសំណើនេះទេ ដោយសារ [redacted] ដែលមិនមែន ជាភាគីនៃកិច្ចដំណើរការនីតិវិធី ពុំមានសិទ្ធិដាក់សំណើបែបនេះនៅពេលនោះទេ[29]។ ពួកគាត់ក៏ បន្ថែមផងដែរថា ខុសពី ក.ស.ព អនុលោមតាមវិធានផ្ទៃក្នុង ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិ ប្ដឹងឧទ្ធរណ៍តែក្នុងករណីមួយចំនួនមានកម្រិតប៉ុណ្ណោះ ដែលមិនរាប់បញ្ចូលនូវសិទ្ធិប្ដឹង ឧទ្ធរណ៍ ចំពោះដីកាសម្រេចរបស់ ក.ស.ច.ស ក្នុងការបញ្ជូនសំណើសុំមោឃភាពដែលភាគីដទៃទៀត បានដាក់នោះឡើយ[30]។

17. អង្គបុរេជំនុំជម្រះយោងទៅលើ៖ បទប្បញ្ញត្តិនានានៃវិធាន ៧៦(២), ៧៦(៣) និង ៧៧ នៃវិធានផ្ទៃក្នុង, មាត្រា ៨ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ និងសេចក្ដីណែនាំរបស់ អ.ប.ជ ថ្ងៃទី ៣ ខែ កញ្ញា។

---

[24] *ដូចយោងខាងលើ* កថាខណ្ឌ ២២។

[25] *ដូចយោងខាងលើ*។

[26] *ដូចយោងខាងលើ* កថាខណ្ឌ ២៣-២៤។

[27] *ដូចយោងខាងលើ* កថាខណ្ឌ ២៥។

[28] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១-២, ១៤-១៨។

[29] ចម្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ១៣ ដែលដកស្រង់ដីកាសម្រេចបញ្ជូនសំណុំរឿងរបស់ ក.ស.ច.ស កថាខណ្ឌ ៣, ៥។

[30] ចម្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ១៤ ដែលដកស្រង់វិធាន ៧៤(៤) នៃវិធានផ្ទៃក្នុង។

18. ពុំមានបទប្បញ្ញត្តិច្បាស់លាស់នៅក្នុងវិធាន ៧៦ នៃវិធានផ្ទៃក្នុង បង្គាប់ឲ្យភាគីដទៃទៀតឆ្លើយតបទៅនឹងសំណើសុំមោឃភាពឡើយ។ មាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (‘CCCP’) ក៏ពុំបានចង្អុលបង្ហាញឲ្យបានច្បាស់បន្ថែមទៀតអំពីបញ្ហានេះដែរ[31]។ លើសពីនេះ ទៀត វិធាន ៧៦(២) នៃវិធានផ្ទៃក្នុងចែងថា សិទ្ធិប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស បែបនេះត្រូវ “អនុលោមតាមវិធានផ្ទៃក្នុងទាំងនេះ”។ ដូចដែលបានកត់សម្គាល់ នៅក្នុងចម្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា វិធាន ៧៤(៤) នៃវិធានផ្ទៃក្នុង ពុំបានផ្ដល់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីនូវសិទ្ធិតាមផ្លូវច្បាប់ ក្នុងការប្ដឹង ឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ទាំងនោះ ដែលបានចេញ អនុលោមតាមវិធាន ៧៦(២) នៃវិធានផ្ទៃក្នុងដែលយល់ព្រមបញ្ជូនសំណើសុំទៅអង្គបុរេជំនុំជម្រះនោះឡើយ។ ទាក់ទិននឹងសហព្រះរាជអាជ្ញាវិញ ខណៈដែលវិធានផ្ទៃក្នុងផ្ដល់ឲ្យពួកគាត់នូវសិទ្ធដែលគ្មាន កម្រិត ក្នុងការប្ដឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចរបស់ ក.ស.ច.ស ទោះបីជាពួកគាត់ ប្ដឹង ឧទ្ធរណ៍ចំពោះដីកាសម្រេចបញ្ជូនសំណុំរឿងរបស់ ក.ស.ច.ស ក៏ដោយ ក៏អ្វីដែលពួកគាត់អាច លើកឡើងបាននោះ (តាមរយៈបណ្ដឹងឧទ្ធរណ៍នោះ) គឺថាតើ ស.ច.ស.អ បានអនុវត្តលក្ខណៈ វិនិច្ឆ័យសម្រាប់ការបញ្ជូនសំណើសុំទៅអង្គបុរេជំនុំជម្រះត្រឹមត្រូវដែរ ឬទេ[32]។ ដូច្នេះ សិទ្ធិប្ដឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង មិនមែនបកស្រាយទៅជាសិទ្ធិ ឬកាតព្វកិច្ចរបស់ ក.ស.ព ក្នុងការឆ្លើយតបទៅនឹងអង្គសេចក្ដីនៃសំណើសុំនោះឡើយ។ ចុងក្រោយ ពុំមានបទប្បញ្ញត្តិច្បាស់លាស់ នៅក្នុងវិធាន ៧៦ នៃវិធានផ្ទៃក្នុង បង្គាប់ដល់អង្គបុរេជំនុំជម្រះអំពីរបៀបក្នុងការបន្តដំណើរការនីតិវិធីនោះឡើយ ឧទា. ថាតើ ត្រូវជូនដំណឹងភាគីដទៃទៀត អំពីសំណើសុំបែបនេះ ឬយ៉ាងណា ឬថាតើ ត្រូវអនុញ្ញាត ឬបង្គាប់ឲ្យភាគីដទៃទៀតឆ្លើយតបទៅ នឹងសំណើសុំ ឬយ៉ាងណា នៅពេលដែល ក.ស.ច.ស បាន

[31] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បកប្រែភាសាខ្មែរ-ភាសាអង់គ្លេស ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៨ (‘CCCP’)។

[32] យោងតាមយុត្តិសាស្ត្រ បទដ្ឋានដែលបានកំណត់សម្រាប់ការពិនិត្យឡើងវិញរបស់ ក.ស.ច.ស ទៅលើសំណើសុំបញ្ជូនពាក្យសុំមោឃភាពទៅ អ.ប.ជ គឺគ្រាន់តែពិនិត្យថាតើ “មានពាក្យសុំមានហេតុផលដែលថាមានកំហុសនីតិវិធីដែរឬទេ ហើយកំហុសនោះរំលោភលើសិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំដែរឬទេ” សំណុំរឿង ០០២ (អបជ៤១) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D263/2/6 (“សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ [redacted]”) កថាខណ្ឌ ១៨។

ប្តឹងទៅ អ.ប.ជ ឲ្យពិនិត្យ និងចាត់ ការលើសំណើសុំមោឃភាព អនុលោមតាមវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង តាមការស្នើសុំ របស់ភាគីនោះ។ ដោយសារពុំមានភាពច្បាស់លាស់បែបនេះហើយ និងដោយបានស្វែងរកការណែនាំពីក្នុងគោលការណ៍នីតិវិធីជាសារវ័ន្តនៅចំពោះមុខ អ.វ.ត.ក នេះ ហើយទើប អង្គបុរេជំនុំ ជម្រះបានចេញសេចក្តីណែនាំរបស់ អ.ប.ជ ថ្ងៃទី ៣ ខែ កញ្ញា ដោយណែនាំ៖ ១) ឲ្យមេធាវីការ ពារក្តី [redacted] ដាក់ពាក្យសុំនៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងរយៈពេល ដប់ថ្ងៃ គិតពីថ្ងៃទទួល បានការជូនដំណឹងអំពីសេចក្តីណែនាំរបស់ អ.ប.ជ នេះ[33] និង ២) ភាគីដទៃទៀតថា៖

> "នៅពេលពាក្យសុំត្រូវបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ឬក៏ពេលវេលាកំណត់បានកន្លងហួស កិច្ចដំណើរការនីតិវិធីលើពាក្យសុំ ត្រូវស្ថិតក្រោមបញ្ញត្តិទូទៅនៃវិធាន ៧៧ នៃវិធានផ្ទៃក្នុង។ តាមធម្មតា តម្រូវការភាសា ពេលវេលា និងទំព័រកំណត់សម្រាប់សារណាដាក់ដោយភាគីពាក់ព័ន្ធនឹងពាក្យសុំនេះ ត្រូវអនុវត្តតាមសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក"[34]។

19. សេចក្តីណែនាំរបស់ អ.ប.ជ ថ្ងៃទី ៣ ខែ កញ្ញា ផ្អែកទៅលើគោលការណ៍ជាសារវ័ន្ត ដែលមានចែងនៅក្នុងវិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង ថា "ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។ គោលការណ៍នៃដំណើរការនីតិវិធីចំពោះមុខ ទាក់ទិនដោយផ្ទាល់ទៅនឹងលក្ខខណ្ឌតម្រូវ សម្រាប់ការជំនុំជម្រះក្តីដោយយុត្តិធម៌[35] ដូចដែលបានចែងទុកនៅក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") និង "តម្រូវថា ភាគីនីមួយៗនៃកិច្ចដំណើរការនីតិវិធីគួរតែទទួលបានឱកាសសមហេតុផលក្នុងការបង្ហាញ

---

[33] សេចក្តីណែនាំរបស់ អ.ប.ជ ថ្ងៃទី ៣ ខែ កញ្ញា កថាខណ្ឌ ២។

[34] *ដូចយោងខាងលើ* កថាខណ្ឌ ៣។

[35] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ (អបជ ៧១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក [redacted] ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក [redacted] ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4 កថាខណ្ឌ ១៨។ នៅក្នុងសាលដីកានេះ អ.ប.ជ បានអនុញ្ញាតឲ្យមេធាវីការពារក្តីដាក់ចម្លើយតបទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់ ក.ស.ព នៅក្នុងសំណុំរឿង ០០២ ទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុងពុំបានចែងច្បាស់អំពីសិទ្ធិបែបនេះក៏ដោយ។

រឿងក្ដីរបស់គាត់នៅក្រោមលក្ខខណ្ឌដែលមិនដាក់គាត់នៅក្នុងស្ថានភាពលំបាកខ្លាំង *ទល់នឹង*គូបដិបក្ខរបស់គាត់នោះឡើយ"[36]។ លើសពីនេះទៀត មានការកត់សម្គាល់ថា វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានចែងទុកអំពីករណីលើកលែងណាមួយចំពោះវិធានដែលថា ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែចំពោះមុខនោះឡើយ។ ទាក់ទិននឹងបញ្ហានេះ អង្គបុរេជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា៖

"ការប្រាស្រ័យទាក់ទងតែភាគីម្ខាងត្រូវបានកំណត់យ៉ាងតឹងរ៉ឹង ដើម្បីធានានូវសិទ្ធិរបស់ភាគីក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក អនុលោមតាមវិធាន ២១.១ នៃវិធានផ្ទៃក្នុង ដែលថា (ក) ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ អង្គ-បុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទស្សនៈរបស់តុលាការអន្តរជាតិដែលថា គេ "ពុំអាច ឬវាពុំមានភាពសមស្របក្នុងការកំណត់កាលៈទេសៈសមស្របនៃកិច្ចដំណើរការនីតិវិធីមានភាគីតែម្ខាង តាមរយៈការកំណត់ណាមួយនោះឡើយ"។ ជាវិធានទូទៅ គេត្រូវដាក់សំណើជាលក្ខណៈអន្តរភាគី បើទោះបីជាការដាក់សំណើដោយភាគីតែម្ខាងអាចមានភាពចាំបាច់សម្រាប់ប្រយោ ជន៍ដល់យុត្តិធម៌ និងក្នុងពេលការផ្សាយចេញព័ត៌មានដែលមាននៅក្នុងសំណើនឹងទំនងជាប៉ះពាល់ទៅដល់បុគ្គល ដែលទាក់ទិននឹងសំណើនោះក្ដី។ ទោះស្ថិតក្នុងកាលៈទេសៈណាក្ដី ការប្រាស្រ័យទាក់ទងជាផ្លូវការដោយភាគីតែម្ខាង ត្រូវធ្វើឡើងក្នុងទម្រង់ជាសំណើ និងត្រូវគោរពនីតិវិធីក្នុងការដាក់សំណើដូចដែលបានរៀបរាប់នៅក្នុងសេចក្ដីណែនាំអនុវត្តពាក់ព័ន្ធ។ ជាមួយគ្នានេះ ត្រូវរៀបរាប់ឱ្យបានច្បាស់លាស់នូវហេតុផលចំពោះការប្រាស្រ័យទាក់ទងតែភាគីម្ខាង អនុលោមតាមសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ និងជាពិសេស មាត្រា ៣.១៥ ដើម្បីអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះអាចពិនិត្យមើលបានតាមការគួរ"[37]។

---

[36] តុលាការសិទ្ធិមនុស្សអឺរ៉ុប *រឿងក្ដី* [redacted] *ទល់នឹង ប្រទេសបែលហ្ស៊ិក* ពាក្យសុំលេខ 32576/96 សាលក្រម ថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០០៣ កថាខណ្ឌ ៣២។

[37] សំណុំរឿង ០០២ (អបជ០៨) សាលដីកាលើសំណើសុំរបស់ [redacted] ឱ្យមានការស៊ើបអង្កេតក្រោមវិធានផ្ទៃក្នុង ៣៥ អំពីទង្វើរបស់ [redacted] នៃការិយាល័យសហព្រះរាជអាជ្ញា ទាក់ទិននឹងការប្រាស្រ័យ ទាក់ទង *ដោយភាគីតែម្ខាង*ជាមួយសមាសភាពអន្តរជាតិនៃ ក.ស.ច.ស និងសំណើសុំឱ្យមានសវនាការជាសាធារណៈ ថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១០ ឯកសារលេខ ៣ កថាខណ្ឌ ១៥។

20. មាត្រា ៣.១៥ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារតម្រូវថា ភាគីដាក់ឯកសារដែលស្នើសុំដាក់ចំណាត់ប្រភេទឯកសារ "សម្ងាត់បំផុត" ត្រូវសរសេររៀបរាប់នៅលើទំព័រទី១ នៃឯកសារដោយដាក់ថា "ជូនចំពោះ" ឈ្មោះបុគ្គលទាំងអស់ ដែលភាគីនោះស្នើសុំឱ្យមានការផ្តល់សិទ្ធិមើលឯកសារ[38]។ នៅក្នុងករណីនេះ មេធាវីការពារក្តីរបស់ [redacted] បានដាក់ពាក្យសុំជាឯកសារសម្ងាត់ តែបានរៀបរាប់នៅក្នុងទំព័រទី១ នូវឈ្មោះរបស់ ស.ច.ស និងមន្ត្រីនៅក្នុង ក.ស.ព និង "ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់" លើកឡើងយ៉ាងច្បាស់ថា ពាក់ព័ន្ធនឹង [redacted] ពុំមានការអះអាងថា មានព្យសនកម្មដែលអាចបណ្តាលមកពីការផ្តល់ព័ត៌មានដល់ភាគីផ្សេងទៀតអំពីពាក្យសុំទេ។

21. ជាងនេះទៀត ការណ៍ដែលថា វិធាន ៧៧(២) នៃវិធានផ្ទៃក្នុងយោងយ៉ាងច្បាស់ទៅលើសេចក្តីសម្រេចនានា អនុលោមតាមវិធាន ៧៦(៣) នៃវិធានផ្ទៃក្នុង បង្ហាញថា ទោះបីវិធាន ៧៦ នៃវិធានផ្ទៃក្នុងត្រឹមតែចែងពីដំណើរការមោឃភាពជារួមក៏ដោយ ក៏វិធាន ៧៧ នៃវិធានផ្ទៃក្នុងគឺជាវិធានដែលប្រមើលមើលពីនីតិវិធីសម្រាប់ដោះស្រាយពាក្យសុំមោឃភាព។ អនុលោមតាមវិធាន ៧៧ នៃវិធានផ្ទៃក្នុង កិច្ចដំណើរការនីតិវិធីសម្រាប់ដោះស្រាយបណ្តឹងឧទ្ធរណ៍ និងពាក្យសុំមានលក្ខណៈតទល់ និយាយម្យ៉ាងទៀត វិធានផ្ទៃក្នុងអំពាវនាវឱ្យមានការសវនាការ ឬ ឱ្យភាគីផ្សេងទៀតដាក់សារណាតប និងចម្លើយតប។

22. បន្ថែមទៅលើចំណុចខាងលើ អង្គបុរេជំនុំជម្រះ បានលើកឡើងយ៉ាងត្រឹមត្រូវ យ៉ាងហោចណាស់នូវក្តីរំពឹងមួយដែលថា អង្គបុរេជំនុំជម្រះនឹងស្តាប់សេចក្តីសន្និដ្ឋានពីភាគីផ្សេងទៀត ទាក់ទិនទៅនឹងមោឃភាព ឬពាក្យសុំស្រដៀងគ្នានេះ[39]។

---

[38] ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិ.លើកទី ៨ មាត្រា ៣.១៥។

[39] *សូមមើល* សេចក្តីសម្រេចលើពាក្យសុំលុបចោលអនុលោមតាមវិធាន ៧៦(១) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D165/1 កថាខណ្ឌ ៣។ សំណុំរឿង ០០៣ (អ.ប.ជ ០៩) សេចក្តីសម្រេចលើពាក្យសុំលុបចោលអនុលោមតាមវិធាន ៧៦(១) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ D79/1 កថាខណ្ឌ ៣។ *សូមមើលផងដែរ* សំណុំរឿង ០០២ (ពាក្យសុំលេខ អ.ប.ជ ១៥) សេចក្តីសម្រេចស្តីពីពាក្យសុំបន្ទាន់បង្ខំរបស់ [redacted] ដែលស្នើឱ្យផ្អាកកិច្ចដំណើរការនីតិវិធីភ្លាម និងជាស្ថាពរចំពោះការបំពានដំណើរការនីតិវិធី ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១១ លេខ ២ កថាខណ្ឌ ១ ដែលលើកឡើងថា "ពុំមានភាគីណាមួយឆ្លើយតបទៅនឹងពាក្យសុំទេ" និងសំណុំរឿង ០០៣ (ពាក្យសុំលេខ អ.ប.ជ ០១) សេចក្តីសម្រេចស្តីពីសំណើរបស់អង្គភាពគាំពារការការពារក្តី ដែលស្នើសុំឱ្យផ្អាកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសំណើសុំវិធានការការពារពាក់ព័ន្ធនឹងការធ្វើជាតំណាងឱ្យមានប្រសិទ្ធភាពដល់ជនសង្ស័យនៅ

*សេចក្តីពិចារណាលើសំណើរបស់ [redacted] សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*

23. ដូចបានលើកឡើងយ៉ាងច្បាស់នៅក្នុងផ្នែក "ប្រវត្តិនីតិវិធី" នៃសេចក្តីពិចារណានេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ស.ព.អ បានដាក់សារណាតបទៅនឹងពាក្យសុំរបស់ [redacted] ទៅតាមកាលបរិច្ឆេទដែលបានកំណត់ដោយសេចក្តីណែនាំរបស់ អ.ប.ជ ថ្ងៃទី ៣ ខែ កញ្ញា។ ជាងនេះទៀត អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យ ស.ព ដាក់ចម្លើយតបយឺតយ៉ាវ ត្រឹមតែនៅពេលកាលបរិច្ឆេទចុងក្រោយសម្រាប់ឱ្យ [redacted] ដាក់សារណាតបទៅនឹងសំណើរបស់ពួកគេ (សុំពន្យារពេលដាក់សារណាតបតែមួយភាសាជាមុនសិន) បានផុតកំណត់។ ដោយមិនបានទទួលព័ត៌មានពី [redacted] អង្គជំនុំជម្រះបានអនុញ្ញាតឱ្យដាក់សារណាយឺតយ៉ាវ ដោយផ្អែកលើសំអាងហេតុសម្រាប់សំណើ និងផ្អែកលើបទប្បញ្ញត្តិនានានៃវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង។

24. យោងទៅលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ ទឡ្ហីករណ៍របស់ [redacted] ដែលថា អង្គបុរេជំនុំជម្រះ ត្រូវតែពិចារណាតែទៅលើទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងសំណើបានហើយ ដោយសារតែ ចម្លើយតបណាមួយទៅនឹងសំណើដែលបានដាក់នៅពេលនេះ គឺពុំបានដាក់ទៅតាមពេលវេលាដែលបានកំណត់នោះ គឺមិនអាចទទួលយកបានទេ។

### III-2 តើអង្គជំនុំជម្រះគួរស្តាប់សេចក្តីសន្និដ្ឋានរបស់ [redacted] នៅក្នុងកិច្ចដំណើរការនីតិវិធីនៃការធ្វើមោឃភាពនាំងនេះ ឬយ៉ាងណា

25. [redacted] ស្នើសុំអង្គបុរេជំនុំជម្រះអនុញ្ញាតឱ្យគាត់ដាក់ "សំណើសុំអនុញ្ញាត" ដាក់សារណា "ដើម្បីគាំទ្រ" ពាក្យសុំរបស់ [redacted][40]។ គាត់បានសំអាង "សំណើសុំការអនុញ្ញាត" របស់គាត់ នៅលើវិធាន ២១ និង៣៩ នៃវិធានផ្ទៃក្នុង[41]។ គាត់លើកជាទឡ្ហីករណ៍ថា វិធាន ២១ នៃវិធានផ្ទៃក្នុងកំណត់ថា គាត់ត្រូវបានទទួលសិទ្ធិស្មើនឹងសិទ្ធិនានាដែលបានផ្តល់ឱ្យភាគីផ្សេងៗទៀត រួមទាំង ក.ស.ព និងដើមបណ្តឹងរដ្ឋប្បវេណី ដែលខុសពីរូបគាត់ ពួកគេបានទទួលការជូនដំណឹងពីសេចក្តីណែនាំរបស់ អ.ប.ជ ចុះថ្ងៃទី ៣ ខែ កញ្ញា ដែលកិច្ចដំណើរការនីតិវិធីទាំងនេះគួរតែត្រូវបានគ្រប់

---

ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ លេខ ៣ កថាខណ្ឌ ២ ដែលលើកឡើងថា "ពុំមានការឆ្លើយតបទៅនឹងសំណើ"។

[40] សំណើ និងសារណារបស់ [redacted] កថាខណ្ឌ ១, ២ និងកថាខណ្ឌចុងក្រោយ (i)។

[41] *ដូចយោងខាងលើ* កថាខណ្ឌ ១។

គ្រងដោយវិធាន ៧៧ នៃវិធានផ្ទៃក្នុង[42]។ គាត់អះអាងថា ការអនុញ្ញាតនេះក៏ត្រូវបានផ្តល់ដែរ ដោយសារសេចក្តីសម្រេចរបស់ អ.ប.ជ ទៅលើពាក្យសុំរបស់ [redacted] "អាចមានអានុភាព ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់លទ្ធផលនៃកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងអ្នកស្រី [redacted]" ដែរ[43]។ ប្រសិនបើអង្គជំនុំជម្រះយល់ស្របទៅនឹងទឡ្ហីករណ៍នានាដែលបានលើកឡើងខាងលើ [redacted] លើកឡើងថា អង្គបុរេជំនុំជម្រះអាចអនុវត្តឆន្ទានុសិទ្ធិដែលត្រូវបានអនុញ្ញាតទៅតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង ដើម្បីទទួលស្គាល់នូវសុពលភាពនៃការដាក់យឺតយ៉ាវនូវសារណាដែលគាត់បានស្នើ[44]។

26. [redacted] មិនបានដាក់ចម្លើយតបណាមួយទៅនឹងសំណើ និងសារណារបស់ [redacted] ទេ។ នៅក្នុងការឆ្លើយតបរបស់គាត់ទៅនឹងសេចក្តីណែនាំរបស់ អ.ប.ជ ថ្ងៃទី ៣ ខែ កញ្ញា [redacted] បានស្នើសុំថា ក.ស.ព ឬ "ភាគីផ្សេងៗទៀត" មិនគួរត្រូវបានអនុញ្ញាតឱ្យដាក់ទឡ្ហីករណ៍ស្តីពីបញ្ហានានាដែលត្រូវបានសម្រេចដោយអង្គជំនុំជម្រះទេ[45]។ ពុំមានភាពច្បាស់លាស់ថាតើ ពាក្យថា "ភាគីផ្សេងៗទៀត" ដែល [redacted] បានប្រើប្រាស់នៅក្នុងការឆ្លើយតបរបស់គាត់ទៅនឹងសេចក្តីណែនាំរបស់ អ.ប.ជ មានគោលបំណងរាប់បញ្ចូល [redacted] ឬយ៉ាងណាទេ ក៏ប៉ុន្តែ ការណ៍ដែលថា នៅលើទំព័រទីមួយ [redacted] បានរៀបរាប់ មិនត្រឹមតែ ស.ច.ស, ក.ស.ព និង "ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់" ទេ ថែមទាំង "សហមេធាវីការពារក្តី [redacted]" ទៀតផង ដែលអាចបង្ហាញពីចេតនារបស់ [redacted] យ៉ាងហោចណាស់ក៏ជូនដំណឹងដល់គាត់ នូវការឆ្លើយតបរបស់ខ្លួនដែរ។

27. ស.ព.អ មិនជំទាស់ទៅនឹងសំណើរបស់ [redacted] ដែលស្នើសុំការអនុញ្ញាតដាក់សំណើទេ ដោយលើកឡើងថា "[redacted] មានចំណាប់អារម្មណ៍ច្បាស់លាស់ នៅក្នុងការស៊ើបអង្កេតនៃការចោទប្រកាន់ចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"[46]។

28. ក្រៅពីនេះ មានការសង្កត់ធ្ងន់ថា សំណើសុំការអនុញ្ញាតដាក់សារណាដែលបានស្នើឡើងនៅពេលនេះ ត្រូវបានគាំទ្រជាក់លាក់នៅក្នុងវិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង ដែលស្នើសុំសិទ្ធិទទួលបាន

---

[42] *ដូចយោងខាងលើ* កថាខណ្ឌ ២ ជើងទំព័រ ៦ ដោយដកស្រង់វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង។

[43] សំណើ និងសារណារបស់ [redacted] កថាខណ្ឌ ២។

[44] *ដូចយោងខាងលើ*។

[45] ការឆ្លើយតបរបស់ [redacted] ទៅនឹងសេចក្តីណែនាំរបស់ អ.ប.ជ កថាខណ្ឌ ៣, ២០, ២៦។

[46] ចម្លើយតបរបស់ ស.ព.អ ទៅនឹង [redacted] កថាខណ្ឌ ២។

01241267



កិច្ចដំណើរការនីតិវិធីដោយយុត្តិធម៌ និងស្មើភាព (ក្នុងន័យតទល់គ្នា)។ ក្នុងន័យនេះ [redacted] ស្នើសុំឱ្យអង្គជំនុំជម្រះស្ដាប់សេចក្ដីសន្និដ្ឋានរបស់គាត់នៅក្នុងកិច្ចដំណើរការនីតិវិធីដែលភាគីផ្សេងៗទៀត (នៃការស៊ើបអង្កេត) ទទួលបានសិទ្ធិក្នុងការស្ដាប់សេចក្ដីសន្និដ្ឋាន។

29. ហេតុនេះអង្គបុរេជំនុំជម្រះ បានយកមកពិចារណានូវសំអាងហេតុនានាដូចតទៅ ដើម្បីទទួលយកសារណាដែលបានស្នើឡើងដោយ [redacted]៖ ១) អ.ប.ជ បានផ្ដល់រួចហើយនូវសិទ្ធិត្រូវបានស្ដាប់សេចក្ដីសន្និដ្ឋាននៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ ដល់ភាគីផ្សេងៗទៀត នៅក្នុងសំណុំរឿង ០០៤ រួមទាំង ស.ព.អ និង ដើមបណ្ដឹងរដ្ឋប្បវេណី, ២) សារណាដែលបានស្នើឡើងដោយ [redacted] មិនបានដាក់នូវទឡ្ហីករណ៍ថ្មី ឬទឡ្ហីករណ៍ផ្សេងៗទៀត ពីទឡ្ហីករណ៍នានាដែល [redacted] បានដាក់រួចហើយ, ៣) សារណារបស់ [redacted] នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះត្រូវបានដាក់យឺតពេល ដោយសារមានកត្តានានាដែលហួសពីការគ្រប់គ្រងរបស់គាត់, ៤) [redacted] បានបំពេញការងារដោយយកចិត្តទុកដាក់នៅពេលគាត់បានដឹងពីកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន ៥) [redacted] មិនបានជំទាស់ជាក់លាក់ទៅនឹងសំណើរបស់ [redacted] ទេ (ទៅតាមកាលបរិច្ឆេទដែលកំណត់ដោយច្បាប់សម្រាប់ចម្លើយតបនេះ) និង ៦) ក.ស.ព មិនជំទាស់ទៅនឹងភាពទទួលយកបាននៃសារណារបស់ [redacted] ទេ។

30. ដោយអនុលោមទៅតាមសំអាងហេតុនានាដែលបានលើកឡើងខាងលើ និងដោយផ្អែកលើ៖ ១) បទប្បញ្ញត្តិនៃវិធាន ៣៩(៤)(ខ) នៃវិធានផ្ទៃក្នុង ដែលផ្ដល់ដល់អង្គជំនុំជម្រះនូវសិទ្ធិអំណាចក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីទទួលស្គាល់សុពលភាពនៃកិច្ចនានាដែលត្រូវបានដំណើរការហួសពេលកំណត់ និង ២) ទៅលើបទប្បញ្ញត្តិនានានៃវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលចែងថា កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ត្រូវតែមានភាពយុត្តិធម៌ និងត្រូវគោរពគោល ការណ៍ចំពោះមុខនោះ អង្គបុរេជំនុំជម្រះបានសម្រេចអនុញ្ញាតឱ្យ [redacted] ដាក់សារណាដែលបានស្នើឡើង ដើម្បីគាំទ្រដល់ពាក្យសុំរបស់ [redacted]។

## IV. ភាពទទួលយកបាននៃពាក្យសុំមោឃភាព

31. វិធាន ៧៦(៤) នៃវិធានផ្ទៃក្នុងណែនាំថា អង្គជំនុំជម្រះអាចប្រកាសថា ពាក្យសុំមោឃភាពនេះមិនអាចទទួលយកបាន ប្រសិនបើពាក្យសុំ៖ ១) មិនបានបង្ហាញហេតុផលគ្រប់គ្រាន់ ២) មានពាក់ព័ន្ធ

ជាមួយដីកាដែលត្រូវប្ដឹងឧទ្ធរណ៍ ឬ ៣) គ្មានមូលដ្ឋានច្បាស់លាស់។ ហេតុនេះ អង្គបុរេជំនុំជម្រះត្រូវបង្ហាញថាតើ ពាក្យសុំមោឃភាព (១) បានបញ្ជាក់ជាក់លាក់នូវផ្នែកនៃកិច្ចដំណើរការនីតិវិធីដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់ដើមបណ្ដឹងឧទ្ធរណ៍[47] (២) បានបង្ហាញច្បាស់ពីការប៉ះពាល់នេះ[48] និង (៣) ក្នុងករណីចាំបាច់ បានបន្ថែមភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការចោទប្រកាន់[49] ឬយ៉ាងណា។

32. ទីមួយ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ពាក្យសុំទាក់ទិននឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនពាក់ព័ន្ធទៅនឹងដីកាបង្គាប់ណាមួយដែលបើកឱ្យប្ដឹងឧទ្ធរណ៍ទេ។ ទីពីរ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា [redacted] បានបង្ហាញនូវការប៉ះពាល់ផលប្រយោជន៍ដែលត្រូវបានចោទប្រកាន់យ៉ាងច្បាស់ដោយលើកជាទឡ្ហីករណ៍ថា រាល់កិច្ចស៊ើបសួរទាំងអស់ដែលទាក់ទិនទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរំលោភដល់សិទ្ធិជាសារវ័ន្តរបស់គាត់ អនុលោមទៅតាមគោលការណ៍នីត្យានុកូលភាពដែលមានចែងនៅក្នុងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយត្រូវយកមកជំនុំជម្រះតែបទល្មើសព្រហ្មទណ្ឌដែលសំដៅដល់សកម្មភាពនានាដែលបង្កើតជាឧក្រិដ្ឋកម្មនៅក្នុងច្បាប់ នៅពេលប្រព្រឹត្តសកម្មភាពទាំងនោះតែប៉ុណ្ណោះ។ បើតាម [redacted] សកម្មភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនបានបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងប្រភេទ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ទេ ហេតុនេះ ការប៉ះពាល់ផលប្រយោជន៍ដែលរងការចោទប្រកាន់បង្កើតឱ្យមានកំហុសនីតិវិធី[50]។ ចុងក្រោយ ទាក់ទិននឹងចំណុចទីបីសម្រាប់ភាពទទួលយកបាន ជាជម្រើសបន្ទាប់បន្សំដែលថា បន្ទុកនៃការបង្ហាញការចោទប្រកាន់ដែលត្រូវបានធ្វើឡើង

---

[47] *សូមមើល* សាលដីកាលើរឿងក្ដី [redacted] កថាខណ្ឌ ២៤៖ "ហេតុដូច្នេះ ពាក្យសុំមោឃភាពត្រូវតែ [...] ឱ្យបានជាក់លាក់ថាតើកិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះណាមួយមានកំហុសនីតិវិធី [...]"។

[48] *សូមមើល* សំណុំរឿង ០០២ (អ.ប.ជ ០៦) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក [redacted] ប្រឆាំងនឹងដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ D55/I/8 ("សាលដីកាលើរឿងក្ដី [redacted]") កថាខណ្ឌ ៤០៖ "ការរំលោភសិទ្ធិ [...] ដែលត្រូវបានទទួលស្គាល់នៅក្នុង ICCPR អាចបង្គ្រប់ជាកំហុសនីតិវិធី [...]។ នៅក្នុងករណីបែបនេះ កិច្ចស៊ើបសួរ ឬកិច្ចរបស់តុលាការអាចចាត់ទុកជាមោឃៈ"។

[49] *សូមមើល* សាលដីកាលើរឿងក្ដី [redacted] កថាខណ្ឌ ៣២ ដោយយោងទៅដល់ការចោទប្រកាន់ជាក់លាក់ដែលមានលក្ខណៈខុសគ្នាពីការចោទប្រកាន់ដែលបានធ្វើឡើងនៅក្នុងពាក្យសុំនេះ។

[50] សំណើ កថាខណ្ឌ ៣៥។

នៅក្នុងពាក្យសុំ ផ្អែកលើលក្ខណៈនៃការចោទប្រកាន់នោះ[51] អង្គបុរេជំនុំជម្រះសន្និដ្ឋានថា នៅក្នុងករណីនេះ ដោយសារពាក្យសុំបង្ហាញការប៉ះពាល់ផលប្រយោជន៍ ដែលរងការចោទប្រកាន់ពីកំហុសលើអង្គច្បាប់នោះ ពុំចាំបាច់ត្រូវបង្ហាញភស្តុតាងដើម្បីគាំទ្រដល់ការចោទប្រកាន់ទេ។

## V. ការពិចារណានៅលើមូលដ្ឋាននានានៃមោឃភាព

33. មោឃភាពត្រូវបានប្រមើលមើលនៅក្នុងវិធាន ៤៨ នៃវិធានផ្ទៃក្នុងដែលចែងថា៖ "កិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធានបញ្ញត្តិដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ"។ ហេតុនេះ ភាពមិនប្រក្រតីនៃនីតិវិធីដែលមិនបង្កឲ្យមានការប៉ះពាល់ផលប្រយោជន៍ដល់អ្នកដាក់ពាក្យសុំ មិននាំឲ្យមានមោឃភាពទេ[52]។

34. អនុលោមតាមមាត្រា ២៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("ក.ន.ព.ក") "នីតិវិធីនានានាំនឹងនាំឲ្យមានមោឃភាពផងដែរ កាលណាការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលចែងដោយក្រមនេះ ឬ បទប្បញ្ញត្តិទាំងឡាយស្ដីពីនីតិវិធីព្រហ្មទណ្ឌ ធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែលទទួលរងការបំពាននេះ។ ឧទាហរណ៍ វិធាន និងទម្រង់ការដែលមានលក្ខណៈសំខាន់នោះមានជាអាទិ៍ វិធានទ និងទម្រង់ការដែលមានបំណងធានាការគោរពសិទ្ធិការពារខ្លួន"។ ក្នុងករណីនេះ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា "ការរំលោភសិទ្ធិរបស់ជនត្រូវចោទ ដែលត្រូវបានទទួលស្គាល់នៅក្នុង ICCPR អាចបង្កប់ជាកំហុសនីតិវិធី ហើយនឹងប៉ះពាល់ដល់ផលប្រយោជន៍របស់ជនត្រូវចោទ។ នៅក្នុងករណីបែបនេះ កិច្ចស៊ើបសួរ ឬកិច្ចរបស់តុលាការអាចចាត់ទុកជា

---

[51] *សូមមើល* សាលដីកាលើរឿងក្ដី [redacted] កថាខណ្ឌ ៣២ ដែលតម្រូវឲ្យមានភស្តុតាងបន្ថែមទៀតសម្រាប់ដាក់ពាក្យសុំមោឃភាព ដោយផ្អែកលើការចោទប្រកាន់ពីភាពលម្អៀង ដោយសារការចោទប្រកាន់ប្រភេទនេះតម្រូវឲ្យមានបទដ្ឋានខ្ពស់នៃការបង្ហាញភស្តុតាង។

[52] សំណុំរឿង ០០៣ (អ.ប.ជ ២០) សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចលើពាក្យសុំរបស់ [redacted] ស្នើឲ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D134/1/10 កថាខណ្ឌ ២៦ ដោយយោងទៅ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D263/2/6 កថាខណ្ឌ ២១។

មោឃៈ"[53]។ "ប្រសិនបើមានការខូចខាតប្រាកដមែន ដំណាក់កាលចុងក្រោយផ្តោតលើការរកឱ្យឃើញផ្នែកណាខ្លះនៃនីតិវិធី ដែលត្រូវធ្វើមោឃភាព"[54]។ ជាងនេះទៀត វិធាន ៧៦(៥) នៃវិធានផ្ទៃក្នុងចែងថា៖ "នៅពេលអង្គបុរេជំនុំជម្រះសម្រេចទុកជាមោឃៈកិច្ចស៊ើបសួរណាមួយ អង្គបុរេជំនុំជម្រះត្រូវសម្រេចថា តើមោឃភាពនោះមានប៉ះពាល់ដល់កិច្ច ឬដីកាដទៃទៀតដែរ ឬទេ"។

## V-1 មូលដ្ឋាននានាសម្រាប់ស្នើសុំមោឃភាព

### សំណើសុំរបស់ [redacted]

35. [redacted] ស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ដែលទាក់ទិននឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ("កិច្ចស៊ើបសួរដែលរងការជំទាស់")[55]។ សំណើរបស់ [redacted] ផ្អែកលើទឡ្ហីករណ៍ដែលថា ការស៊ើបអង្កេតទាំងនេះមានកំហុស ដោយសាររំលោភទៅលើសិទ្ធិជាសារវ័ន្តរបស់គាត់ តាមមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលអាចអនុវត្តបាននៅ អ.វ.ត.ក[56] និងដែលតម្រូវថា "គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្រប តាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នា នេះ មិនត្រូវដាក់ទោសឱ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើស ឡើយ" ("គោលការណ៍នីត្យានុកូលភាព")[57]។ ដំបូង [redacted] កត់សម្គាល់ថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬ នៅក្នុងមាត្រា ៧ នៃលក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលចែងពីនិយមន័យជាធរមានចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អនុលោមតាមមាត្រា ៩ នៃកិច្ចព្រមព្រៀងស្តីពីការ

---

[53] សាលដីកាលើរឿងក្តី [redacted] កថាខណ្ឌ ៤០ (គូសបញ្ជាក់បន្ថែម)។

[54] សំណុំរឿង ០០៣ (អ.ប.ជ ២០) សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចលើពាក្យសុំរបស់ [redacted] ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D134/1/10 កថាខណ្ឌ ២៧។

[55] សំណើ កថាខណ្ឌ ៥០។

[56] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣(ថ្មី)។

[57] សំណើ កថាខណ្ឌ ១, ២១ ដល់ ២៦, ៣៣ និង ៣៥។

បង្កើត អ.វ.ត.ក[58]។ [redacted] លើកជាទឡ្ហីករណ៍ថា ទោះបីអំពើនេះត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏មាត្រាទាំងនេះត្រឹមតែបង្កើតជាព្រំដែនសម្រាប់យុត្តាធិការលើបទល្មើសរបស់ អ.វ.ត.ក ប៉ុណ្ណោះ និងមិនបានបង្កើតឧក្រិដ្ឋកម្មទេ[59]។ ហេតុនេះអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានយកមកជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក ទេ ដោយសារគោលការណ៍នីត្យានុកូលភាព "ហាមឃាត់ការធ្វើប្រតិ សកម្មឧក្រិដ្ឋកម្ម" និងការពង្រីកតាមសទិសភាព[60]។ ទោះបី តុលាការអាចបញ្ជាក់បំភ្លឺពីច្បាប់ជាអត្ថិភាពក៏ដោយ ក៏ការប្រព្រឹត្តិដែលត្រូវបានហាមឃាត់ត្រូវតែមានភាពជាក់លាក់ពេញលេញ ដើម្បីឱ្យអង្គសេចក្តីនៃច្បាប់អាចអនុវត្តដែលអាចឱ្យជនជាប់ចោទអាចប្រមើលមើលបានថា ទង្វើទាំងនោះជាបទល្មើសព្រហ្មទណ្ឌ និងអាចដឹងឮបានថា ទង្វើទាំងនោះនឹងត្រូវយកមកផ្តន្ទាទោស នៅពេលប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់[61]។

36. បន្ទាប់ពីមានទឡ្ហីករណ៍នេះ [redacted] យល់ស្របថា សំណើរបស់សហព្រះរាជអាជ្ញា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលស្នើសុំឱ្យ ក.ស.ច.ស ស៊ើបអង្កេតទៅលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងទម្រង់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងប្រភេទនៃអំពើអមនុស្សធម៌ផ្សេងៗទៀត គឺជា "ការព្យាយាមមិនស្របច្បាប់ក្នុងការពង្រីកយុត្តាធិការរបស់តុលាការ"[62] ហើយថា "វិធីសាស្ត្រក្នុងសំណុំរឿង ០០២/០១" ដែល អ.ប.ជ និង អ.ជ.ស.ដ យកមកអនុវត្ត "មិនបានបំពេញតាមលក្ខខណ្ឌតម្រូវទីពីររបស់ អ.ជ.ត.ក សម្រាប់យុត្តាធិការទេ" ពោលគឺថា បទល្មើសនានាដែលត្រូវបានចោទប្រកាន់ត្រូវតែមានក្នុងច្បាប់នៅចន្លោះពីថ្ងៃទី ១៧ ខែ

[58] សំណើ កថាខណ្ឌ ១៨ ដល់ ១៩។

[59] *ដូចយោងខាងលើ*។

[60] សំណើ កថាខណ្ឌ ២១ (គូសបញ្ជាក់បន្ថែម) *ដកស្រង់* Antonio Cassese, *International Criminal Law*, Oxford University Press, 2003 ទំព័រ ១៤៥ ដល់ ១៤៧, ១៥៣ ដល់ ១៥៤។ ដកស្រង់ផងដែរពីសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក (អ.ជ.ត.ក) សាលដីកា ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ៩១ ("សាលដីកាលើសំណុំរឿង ០០១")។

[61] *ដូចយោងខាងលើ ដកស្រង់* សាលដីកាលើសំណុំរឿង ០០១ កថាខណ្ឌ ៩៥, ៩៦។

[62] សំណើ កថាខណ្ឌ ៣៥។

មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩[63]។ [redacted] បង្កើតទឡ្ហីករណ៍របស់ខ្លួនដោយផ្អែកលើមូលដ្ឋានចំនួនបី៖

37. **មូលដ្ឋាន ក៖ ការរៀប**អាពាហ៍ពិពាហ៍**ដោយបង្ខំពុំមានអត្ថិភាពនៅក្នុងច្បាប់ជាទ**ម្រង់*ឧក្រិដ្ឋកម្ម* **ប្រឆាំងមនុស្សជាតិក្នុងប្រភេទ "អំពើអមនុស្សធម៌ផ្សេងទៀត" នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩**[64]។ យោងតាមមូលដ្ឋាននេះ [redacted] សន្និដ្ឋានថា៖ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ពុំមានចែងអំពីការរៀបអាពិពាហ៍ពិពាហ៍បង្ខំនោះទេ។ ប្រទេសកម្ពុជាពុំមែនជាភាគីនៃសន្ធិ សញ្ញាទាក់ទងនឹងការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំ ហើយ ជាក់ស្តែង សន្ធិសញ្ញាបែបនេះពុំមានអត្ថិភាពនៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ នោះឡើយ[65]។ [redacted] បន្តផ្តល់ទឡ្ហីករណ៍ទៀតថា ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយហេតុ ថា៖ "i) ចំណុចទីមួយ មិនមានការអនុវត្ត ឬ និយាមដែលបានកំណត់ក្នុងចំណោមរដ្ឋ ហើយមិន មានអនុសញ្ញា ឬ សន្ធិសញ្ញាអន្តរជាតិ ដែលអាចកំណត់អត្តសញ្ញាណណាមួយដែលចាត់ទុកការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំថាជាបទឧក្រិដ្ឋនោះឡើយ។ បើទោះបីជាលិខិតុបករណ៍សិទ្ធិមនុស្សចំនួនបីគឺ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (លិខិតុបករណ៍ដែលមិនចងកាតព្វកិច្ច) អនុសញ្ញាស្តីពី

[63] សំណើ កថាខណ្ឌ ៣៥ ដកស្រង់ សាលដីកាលើសំណុំរឿង ០០១ កថាខណ្ឌ ៩៨ ដល់ ១០០ ដែលលើកឡើងថា "ដើម្បីឱ្យបទល្មើសដែលត្រូវបានចោទប្រកាន់ និងទម្រង់នៃការចូលរួមស្ថិតនៅក្នុងយុត្តាធិការនៃរឿងក្តីរបស់ អ.វ.ត.ក បទល្មើស និងទម្រង់នៃការចូលរួមទាំងនោះត្រូវតែ៖ ១) "មានចែងនៅក្នុង [ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក] ដោយច្បាស់លាស់ ឬដោយប្រយោល" *និង* ២) មានអត្ថិភាពក្រោមច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិ នៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩"។ សូមមើលផងដែរ ពាក្យសុំ កថាខណ្ឌ ២៧ (ពិពណ៌នាពី "វិធីសាស្ត្រនៅក្នុងសំណុំរឿង ០០២/០១") ដោយយោងដល់ សំណុំរឿង ០០២ (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 ("សាលដីកាលើសំណុំរឿង ០០២/អ.ប.ជ ៧៥") កថាខណ្ឌ ៣៧១, ៣៧៨; សំណុំរឿង ០០២ (អ.ប.ជ ១៤៥ និង ១៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ [redacted] និង [redacted] ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15 ឯកសារ D427/3/15 ("សាលដីកាលើសំណុំរឿង ០០២/អ.ប.ជ ១៤៥ និង ១៤៦") កថាខណ្ឌ ១៥៦ និងសំណុំរឿង ០០២/១៩-០៩-២០០៧ (អ.ជ.ស.ដ) សាលក្រមលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៣៦ ("សាលក្រមលើសំណុំរឿង ០០២/០១")។

[64] ពាក្យសុំ កថាខណ្ឌ ៣៥, ៣៨-៤៣។

[65] ពាក្យសុំ កថាខណ្ឌ ៣៨។

ការព្រមព្រៀងរៀបអាពាហ៍ពិពាហ៍ កម្រិតអាយុអប្បបរមាសម្រាប់ការរៀបអាពាហ៍ពិពាហ៍ និងការចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ និងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានបញ្ជាក់ថា ការព្រមព្រៀងគឺជាលក្ខខណ្ឌតម្រូវសម្រាប់ការរៀបអាពាហ៍ ពិពាហ៍ក៏ដោយ ក៏លិខិតុបករណ៍ទាំងអស់នេះមិនបានកំណត់ជាក់លាក់ថា ការរៀបអាពិពាហ៍ ពិពាហ៍ដោយបង្ខំគឺជាបទឧក្រិដ្ឋឡើយ។ បន្ថែមលើនេះ លិខិតុបករណ៍សិទ្ធិមនុស្សតែមួយមិន បានផ្តល់នូវភ័ស្តុតាងគ្រប់គ្រាន់អំពីនិយាមដែលបានមានការទទួលស្គាល់ឡើយ”[66] ហើយ ii) “ចំណុចទីពីរ ពុំមានតុលាការអន្តរជាតិណាមួយបានទទួលស្គាល់ការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ក្រៅពី [តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន] តុលាការពិសេសសេរ៉ាឡេអូនដែលមានយុត្តាធិការលើពេលវេលាថ្មីជាងគេ (ក្រោយខែវិច្ឆិកា ឆ្នាំ ១៩៩៦) [ដូច្នេះ សេចក្តីសម្រេចរបស់តុលាការពិសេសនេះពុំអាចយកមកអនុវត្តបាននៅ អ.វ.ត.ក] និងដែលមិនបានផ្តល់នូវសំអាងហេតុគ្រប់គ្រាន់ និងការគាំទ្រគ្រប់ គ្រាន់ ក្នុងសេចក្តីសម្រេចរបស់ខ្លួន” ពីព្រោះថា តុលាការពិសេសនេះ “មិនបានពិនិត្យមើលលើនីត្យានុកូលភាពនៃការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំហួសពីការវិភាគនីត្យានុកូលភាពនៃប្រភេទ “អំពើអមនុស្សធម៌ដទៃទៀត” ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” ហើយ “ក៏ពុំបានធ្វើការសម្រេចថា នៅពេលណាដែលការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានកំណត់ថាជាបទ ឧក្រិដ្ឋដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរ”[67]។

38. **មូលដ្ឋាន ខ៖ [redacted] មិនអាចប្រមើលមើល និងដឹងថាមានច្បាប់ចែងនៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៩៧ ថា អំពើនៃការរៀប**អាពិពាហ៍ពិពាហ៍**ដោយបង្ខំអាចនាំឱ្យមានការទទួលខុស ត្រូវព្រហ្មទណ្ឌ**[68]។ នៅក្នុងកថាខណ្ឌ ៤៤ នៃពាក្យសុំ [redacted] យោងលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក ដែលបានលើកឡើងថា “ចំពោះភាពអាចប្រមើល មើល [...] [ជនជាប់ចោទ] ចាំបាច់ដឹងថាអំពើដែលខ្លួនប្រព្រឹត្តគឺជាអំពើព្រហ្មទណ្ឌក្នុងន័យដែលគេអាចយល់ដឹងជាទូទៅដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយនោះទេ” ហើយ “[ពាក់]ព័ន្ធ

---

[66] ពាក្យសុំ កថាខណ្ឌ ៤០ (ការគូសបញ្ជាក់បន្ថែម) ដកស្រង់ និងបន្តដកស្រង់រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stakić* សំណុំរឿងលេខ IT-97-24-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ៧២១។

[67] ពាក្យសុំ កថាខណ្ឌ ៤១-៤២ ដកស្រង់រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Brima, Kamara & Kanu* សំណុំរឿងលេខ SCSL-2004-16-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ១៩៨, ២០២ (“សាលដីកា *Brima*”)។

[68] ពាក្យសុំ កថាខណ្ឌ ៣៥, ៤៤-៤៥។

នឹងភាពអាចដឹងថាមានច្បាប់ចែង [...] ក្រៅពីច្បាប់សន្ធិសញ្ញា ច្បាប់ផ្អែកលើទំនៀមទម្លាប់ ឬគោលការណ៍ទូទៅអាចយកមកសំអាងថា ជនជាប់ចោទអាចដឹងឮបានគ្រប់គ្រាន់"[69]។ [redacted] អះអាងថា នៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ធាតុផ្សំនៃការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំពុំត្រូវបានកំណត់និយមន័យច្បាស់លាស់ ហើយ [redacted] មិនអាចប្រមើលមើល ឬដឹងច្បាប់ចែងថា ប្រភេទនៃអំពើនេះត្រូវបានហាមឃាត់ និងអាចទទួលទោសនោះឡើយ។ អត្ថិភាពនៃសិទ្ធិស្ដីពីការព្រមព្រៀងលើការរៀបអាពិពាហ៍ពិពាហ៍ ពុំបានជូនដំណឹងគ្រប់គ្រាន់ដល់ [redacted] អំពីលទ្ធភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌលើការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំនោះទេ[70]។

39. **មូលដ្ឋាន គ៖ បើទោះជា អ.វ.ត.ក បំពេញកិច្ចត្រឹមត្រូវ "ក្នុងការអនុម័តយកដោយប្រតិសកម្មចំពោះនិយមន័យនៃការរៀបអាពិពាហ៍ពិពាហ៍ ដោយបង្ខំ [...] ក៏អំពើបែបនេះមិនមាន "លក្ខណៈ និងស្ថានទម្ងន់ប្រហាក់ប្រហែលគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងដទៃ ទៀតឡើយ"**[71]។ បើទោះជាការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំ "ជាអំពើមិនស្របច្បាប់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ក៏ដោយ ក៏ចរិកលក្ខណៈបែបនេះនឹងមិនអាចបំពេញបានតាមធាតុផ្សំនៃ "អំពើអមនុស្សធម៌ដទៃទៀត" ដោយសារតែវាមិនមានភាពធ្ងន់ធ្ងរ ឬអាក្រក់គ្រប់គ្រាន់ដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានរៀបរាប់នោះដែរ"[72]។ ចំណុចទីមួយ កង្វះនៃការកំណត់ជាបទឧក្រិដ្ឋត្រូវបានបង្ហាញជា "ភ័ស្តុតាងមិនអាចប្រកែកបានថា ការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានគេមើលឃើញថា មានភាពធ្ងន់ធ្ងរឡើយនៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩"[73]។ ចំណុចទីពីរ ការរៀបអាពិពាហ៍ ពិពាហ៍ដោយបង្ខំ "ក៏មិនអាចញែកឲ្យដាច់ពីគ្នាពីការរៀបអាពិពាហ៍ពិពាហ៍ក្រោមការរៀបចំ ដែលជាការអនុវត្តន៍ជាទូទៅ និងអាចទទួលយកបាននៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ដែរ" ហើយភាពខុស

[69] ពាក្យសុំ កថាខណ្ឌ ៤៤ *យោងលើ*សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៩៦ *ដកស្រង់ រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Hadžihasanović & Kubura* សំណុំរឿងលេខ IT-01-47 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខបន្ទាន់បង្គំជំទាស់នឹងយុត្តាធិការទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ៣៤។

[70] ពាក្យសុំ កថាខណ្ឌ ៤៥ ដកស្រង់ សាលដីកា *លើរឿងក្ដី Brima* មតិជំទាស់របស់ចៅក្រម Doherty កថាខណ្ឌ ៧១។

[71] ពាក្យសុំ កថាខណ្ឌ ៣៦, ៤៦-៤៩។

[72] ពាក្យសុំ កថាខណ្ឌ ៤៦។

[73] ពាក្យសុំ កថាខណ្ឌ ៤៧។

គ្នាដោយផ្អែកលើការមិនមានការយល់ព្រមដោយផ្ទាល់ពីភាគី "គឺមិនមានភាពច្បាស់លាស់ទាល់តែសោះ"[74]។ ការរៀបអាពាហ៍ពិពាហ៍ក្រោមការរៀបចំក៏ "អាចមានការបង្ខិតបង្ខំ ដូចជាការដាក់សំពាធផ្លូវចិត្តធ្ងន់ធ្ងរ និងការប្រើប្រាស់ល្បិច ការគម្រាម កំហែងមិនទទួលស្គាល់ ឬ ការបណ្តេញចេញពីក្រុមគ្រួសារ និងការភ័យខ្លាចការរើសអើង ពី សហគមន៍"[75]។ ចំណុចទីបី "បើទោះបីជាការរំលោភបំពានបែបនេះទៅលើស្វ័យភាពរបស់ បុគ្គល ព្រមទាំងសិទ្ធិស្វ័យសម្រេចអាចមានគ្រោះថ្នាក់ក៏ដោយ ក៏ព្យសនកម្មដែលកើតចេញពីបញ្ហាទាំងនេះមិនអាចប្រៀបធៀបបានជាមួយនឹងព្យសនកម្ម ដែលបានកើតឡើងពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាក់លាក់នោះដែរ"[76]។

**សេចក្តីសន្និដ្ឋានរបស់ [redacted] គាំទ្រលើពាក្យសុំ៖**[77]

40. នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន [redacted] ស្នើសុំដំណោះស្រាយដូច [redacted] ពោលគឺ អង្គជំនុំបុរេជម្រះមោឃៈកិច្ចស៊ើបសួរទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងសំណុំរឿង ០០៤។ គាត់ស្នើសុំដូច្នេះតាមរយៈការលើកឡើងទឡ្ហីករណ៍ចំបងដូចគ្នាថា កិច្ចស៊ើបសួរបែបនេះរំលោភលើគោលការណ៍នីត្យានុកូលភាព និងសិទ្ធិរបស់ជនត្រូវចោទអនុលោមតាមមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិ ហើយនឹងសិទ្ធិរបស់ពួកគេក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់។ មិនខុសពី [redacted], [redacted] សន្និដ្ឋានថា "គោលការណ៍នីត្យានុកូលភាពត្រូវតែយកមកអនុវត្តទៅលើប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" និងអំពើអមនុស្សធម៌ដែលបានហាមឃាត់ផ្សេងៗនៅក្នុងប្រភេទនេះ"[78]។ យោងតាម [redacted] "ភាពមិនច្បាស់លាស់នៃប្រភេទ "អំពើអមនុស្សធម៌ផ្សេងៗទៀត" របស់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនស្របទៅនឹងគោលការណ៍នីត្យានុកូលភាពនៃច្បាប់ឡើយ"[79]។ [redacted] យកតាមទឡ្ហីករណ៍ផ្សេងទៀតដែល [redacted] បានលើកឡើង[80] ហើយ

---

[74] ពាក្យសុំ កថាខណ្ឌ ៤៨។

[75] *ដូចយោងខាងលើ*។

[76] ពាក្យសុំ កថាខណ្ឌ ៤៩។

[77] សំណើសុំ និងសេចក្តីសន្និដ្ឋានរបស់ [redacted] កថាខណ្ឌ ៣-១០។

[78] ដូចយោងខាងលើ កថាខណ្ឌ ៦។ ពាក្យសុំ កថាខណ្ឌ ២៧-៣២។

[79] ដូចយោងខាងលើ កថាខណ្ឌ ៧។

[80] ដូចយោងខាងលើ កថាខណ្ឌ ៨ *ដកស្រង់* ពាក្យសុំ កថាខណ្ឌ ២៧-៣២ និង ៣៨-៤៩។

សន្និដ្ឋានថា "អង្គបុរេជំនុំជម្រះគួរតែដោះស្រាយបញ្ហាថាតើ អ.វ.ត.ក មានយុត្តាធិការក្នុងការស៊ើបអង្កេត និងធ្វើការកាត់ទោសលើបទចោទពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំនេះដែរ ឬទេ"[81]។

## V-2. ចម្លើយតបទៅនឹងពាក្យសុំ

### ចម្លើយតបរបស់សហព្រះរាជអាជ្ញា

41. សហព្រះរាជអាជ្ញាអន្តរជាតិស្នើឱ្យអង្គបុរេជំនុំជម្រះច្រានចោលពាក្យសុំមោឃភាព ដោយផ្អែកលើមូលដ្ឋានថា ការស៊ើបអង្កេតលើអំពើនៃការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំពុំបង្កឱ្យមានព្យសនកម្មលើម្ចាស់ពាក្យសុំនោះទេ[82]។ ស.ព.អ សន្និដ្ឋានថា វិធីសាស្ត្រក្នុងសំណុំរឿង ០០២/០១ ចំពោះគោលការណ៍នីត្យានុកូលភាពទទួលបានការគាំទ្រពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយហេតុដូច្នេះ អ.វ.ត.ក មានយុត្តាធិការលើបទល្មើសនោះ[83]។ យោងតាម ស.ព.អ "គោលការណ៍នីត្យានុកូលភាព "ពុំរារាំងតុលាការមួយ មិនថានៅថ្នាក់ជាតិ ឬអន្តរជាតិមិនឱ្យធ្វើការសម្រេចលើបញ្ហាណាមួយតាមរយៈវិធីបកស្រាយ និងបញ្ជាក់បំភ្លឺអំពីធាតុផ្សំនៃបទឧក្រិដ្ឋជាក់លាក់ណាមួយនោះទេ" ឬ "ចំពោះអត្ថន័យដែលត្រូវកំណត់លើធាតុផ្សំជាក់លាក់នៃ ឧក្រិដ្ឋកម្មមួយទេ"[84]។ ពួកគេពន្យល់ថា "ការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំបំពេញលក្ខខណ្ឌដែលបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសសេរ៉ាឡេអូន ដូចបាន លើក ឡើងនៅក្នុងកថាខណ្ឌ ១៩៨ នៃសាលដីការបស់ខ្លួននៅក្នុងរឿងក្តី *Brima* និងអ្នកផ្សេងទៀត។ ធាតុផ្សំនៃលក្ខខណ្ឌនោះមិនកម្រិតត្រឹមយុត្តាធិការពេលវេលានៃតុលាការពិសេសសេរ៉ាឡេអូននោះហើយ ហើយមិនកំណត់ត្រឹមការអនុវត្តដូចគ្នានៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ នោះដែរ"[85]។ យោងតាម ស.ព.អ សញ្ញាណនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" បានបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរ

---

[81] ដូចយោងខាងលើ កថាខណ្ឌ ៩-១០។

[82] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៩-៤៣។

[83] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៩-២៤។

[84] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៤ *ដកស្រង់ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Aleksovski* សាលដីកាអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២000 កថាខណ្ឌ ១២៧។

[85] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៤។

ជាតិ ចាប់ពីមុនអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ មកម្លេះ[86]។ ពួកគេបានបន្តពន្យល់បន្ថែមយ៉ាងលម្អិតអំពីហេតុផលដែលអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំខុសពីអំពើនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ហើយអំពើនៃការរៀបអាពាហ៍ពិពាហ៍ក្រោមការរៀបចំ[87]។ ចំណុចចុងក្រោយ នៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងយុត្តាធិការពេលវេលានៃ អ.វ.ត.ក ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានបង្កឱ្យមានការឈឺចាប់ផ្លូវចិត្ត ឬរាងកាយធ្ងន់ធ្ងរ[88] ហើយគឺជាអំពើទាំងឡាយប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារទូទៅ និងជាលក្ខណៈប្រព័ន្ធមកលើជនស៊ីវិលក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមដែលបានបណ្តាលឱ្យមានផលវិបាក ដូចជា អំពើហិង្សាលើរូបរាងកាយដូចៗគ្នា អំពើហិង្សាផ្លូវភេទ ការអប់រំកែប្រែ ឬមរណភាព[89]។ ផលវិបាកទាំងនេះក៏ "ជាផ្នែកមួយនៃគោលនយោបាយកំណត់គោលការណ៍លើប្រជាជនស៊ីវិល ដោយផ្អែកលើមូលហេតុនយោបាយក្នុងការត្រួតត្រាប្រជាជនស៊ីវិល និងដើម្បីធានាឱ្យមានពលករសម្រាប់ពេលអនាគត"[90] ហើយគឺជាអំពើ "មានភាពប្រហាក់ប្រហែល និងមានស្ថានទម្ងន់ដូចគ្នា" ទៅនឹង "ប្រភេទនៃសកម្មភាពដែលត្រូវបានរកឃើញកន្លងមកថាជា "អំពើអមនុស្សធម៌ដទៃទៀត" ដោយតុលាការអន្តរជាតិ ដូចជា ការជម្លៀសដោយបង្ខំ ពេស្យាកម្មដោយបង្ខំ ឬ ការសម្រាតសំលៀកបំពាក់ដោយបង្ខំ"[91]។ ចំពោះនិយមន័យនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ស.ព.អ បានយោងលើនិយមន័យដែលត្រូវបានប្រើប្រាស់ ដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសសេរ៉ាឡេអូន។ និយមន័យនោះចែងថា៖ "អាពាហ៍ពិពាហ៍ដោយបង្ខំពិពណ៌នាពីស្ថានភាពមួយដែលនៅក្នុងនោះ - ដោយពាក្យសម្តី ឬ ដោយអាកប្បកិរិយា - ជនប្រព្រឹត្តបទល្មើស ឬបុគ្គលដែលទទួលខុសត្រូវចំពោះអំពើរបស់ជនប្រព្រឹត្តបទល្មើសបានបង្ខិតបង្ខំបុគ្គលណាម្នាក់ដោយប្រើកម្លាំង ដោយការគំរាមកំហែងថានឹងប្រើកម្លាំង ឬ ដោយការបង្ខំឱ្យបម្រើជាដៃគូប្តី-ប្រពន្ធ បណ្តាលឱ្យ

[86] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២១។

[87] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៥-៣៦។

[88] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៣៧-៣៩។

[89] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៤០។

[90] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៤១។

[91] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៤២ ដកស្រង់ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-4-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៦៨៥-៦៨៧។

01241278



មានជាការឈឺចាប់ធ្ងន់ធ្ងរ ឬជារបួសតាមផ្លូវកាយ តាមផ្លូវចិត្ត ឬតាមផ្លូវអារម្មណ៍ដល់ជនរងគ្រោះ"[92]។

**ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

42. យោងតាមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី "វិធីសាស្ត្រនៅក្នុងសំណុំរឿង ០០២/០១ ដែល [redacted] តវ៉ាជំទាស់ ពុំរំលោភគោលការណ៍នីត្យានុកូលភាពនោះឡើយ។ ការទទួលស្គាល់នៃអំពើអមនុស្សធម៌ផ្សេងទៀតថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យោងតាមប្រភេទរបស់វា ផ្ទាល់ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺស្របគ្នាជាមួយនឹងយុត្តិសាស្ត្រអន្តរជាតិដែលបានបង្កើតឡើងយ៉ាងត្រឹមត្រូវ និងយូរមកហើយដែលមានដើមកំណើតនៅក្នុងធម្មនុញ្ញនូរ៉ឹមប៊ឺកសម្រាប់សាលាក្តីយោធាអន្តរជាតិ ហើយពុំមែនត្រឹមតែ [អង្គបុរេជំនុំជម្រះ] និងអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះនោះទេដែលគោរពតាមសាលាក្តីអន្តរជាតិធំៗទាំងអស់ក្រោយឆ្នាំ ១៩៤៥ ក៏បានគោរពតាមផងដែរ"[93]។ គិតមកត្រឹម "ឆ្នាំ ១៩៧៥ ធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀតមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ និងអាចឱ្យ [redacted] ប្រមើលមើលបានថា ការអនុវត្តគោលនយោបាយនៅទូទាំងប្រទេសដែលបានបង្កនូវការខូចខាត និងការឈឺចាប់ក្នុងចំណោមប្រជាជនស៊ីវិលអាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[94]។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមានស្ថានទម្ងន់ប្រហាក់ប្រហែលគ្នានឹងអំពើទាំងឡាយ ដូចមានចែងនៅក្នុងឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ហើយការអះអាងរបស់ [redacted] លើករណីនេះធ្វើឡើងមុនដំណាក់កាលនីតិវិធីនៅក្នុងដំណាក់កាលនេះដោយហេតុថា ក.ស.ច.ស អាចវាយតម្លៃលើស្ថានភាពប្រហាក់ប្រហែលគ្នានៃការរៀបការដោយបង្ខំ ដោយផ្អែកលើមូលដ្ឋាននៃសំណុំអង្គហេតុស្ថាពរនៅពេលបញ្ចប់កិច្ចស៊ើបសួរក្រោយពេលចេញដីកាដំណោះស្រាយតែប៉ុណ្ណោះ[95]។

---

[92] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៦ *ដកស្រង់* សាលដីកាលើ *រឿងក្តី* *Brima* កថាខណ្ឌ ១៩១។

[93] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៤។

[94] *ដូចយោងខាងលើ* កថាខណ្ឌ ២៥ *យោងលើ* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ D427/1/30 កថាខណ្ឌ ៣៨៥។

[95] *ដូចយោងខាងលើ* កថាខណ្ឌ ២៧-៣៨។

## V-3. ការវាយតម្លៃលើអង្គសេចក្តីរបស់អង្គបុរេជំនុំជម្រះ÷

43. បន្ទាប់ពីពិភាក្សារួចមក ចៅក្រមនៃអង្គបុរេជំនុំជម្រះមិនអាចរកបានមតិភាគច្រើនដើម្បីធ្វើសេចក្តីសម្រេចទៅលើអង្គសេចក្តីនៃសំណើនេះបានឡើយ។

44. ដូច្នេះ ទោះបីជាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចំពោះភាពអាចទទួលយកបាននៃសំណើនេះមានបញ្ជាក់នៅក្នុងកថាខណ្ឌខាងមុខយ៉ាងណាក៏ដោយ ក៏មានការភ្ជាប់បន្ថែមមកជាមួយនូវយោបល់ដាច់ដោយឡែករបស់ចៅក្រមនានានៃអង្គបុរេជំនុំជម្រះ ទាក់ទិននឹងអង្គសេចក្តីនៃសំណើនេះ តាមលក្ខខណ្ឌតម្រូវនៃវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង។

## សេចក្តីសម្រេច

**ដោយផ្អែកលើហេតុផលទាំងនេះ អង្គបុរេជំនុំជម្រះយោងតាមសំឡេងឯកច្ឆន្ទ៖**

១. **យល់ឃើញថា** សំណើនេះអាចទទួលយកបាន។

២. **ប្រកាសថា** អង្គជំនុំជម្រះមិនអាចរកបានសំឡេងគាំទ្រពីចៅក្រម៤(បួន)រូប យ៉ាងតិចដើម្បីចេញសេចក្តីសម្រេចមួយទៅលើអង្គសេចក្តីនៃសំណើនេះបានឡើយ។

**រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន៉ី ថុល** **Kang Jin BAIK** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និង ចៅក្រម ហួត វុទ្ធី សូមលើកឡើងនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍។ ចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK សូមលើកឡើងនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍។

សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ២១)

ឯកសារលេខ D257/1/8

# មតិយោបល់លើអង្គសេចក្ដីនៃពាក្យសុំរបស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និង ចៅក្រម ហួត វុទ្ធី

1. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ ("អ.វ.ត.ក") នឹងបង្ហាញអំពីមតិយោបល់របស់ខ្លួនទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍របស់លោក អោ អាន។ យ៉ាងណាក៏ដោយ ជាការចាប់ផ្ដើម យើងសូមធ្វើការបញ្ជាក់ អំពីការយល់ឃើញរបស់យើងចំពោះការផ្សព្វផ្សាយជាសាធារណៈនៃសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

2. អនុលោមតាមមាត្រា ៣.១២ នៃសេចក្ដីណែនាំអនុវត្ត អ.វ.ត.ក ផ្ដល់សិទ្ធិឱ្យ [redacted] អាចស្នើសុំអង្គបុរេជំនុំជម្រះធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញជា "សាធារណៈ" នូវឯកសារ "សំងាត់" ឬ "សំងាត់បំផុត" ដោយអនុលោមតាមបទប្បញ្ញត្តិនៃសេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង។

3. មាត្រា ៣.១២ វាក្យខណ្ឌទី២ នៃសេចក្ដីណែនាំអនុវត្តរបស់ អ.វ.ត.ក បានចែងថា "តាមករណីសមស្រប ទាល់តែមានការចេញដីកាដំណោះស្រាយ និងសេចក្ដីសម្រេចប្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ ទើបសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះត្រូវពិនិត្យពិចារណាថាតើចំណាត់ថ្នាក់ប្រភេទឯកសារដែលបានស្នើសុំនោះមានលក្ខណៈសមស្របដែរឬទេ ហើយបើសិនជាមិនសមស្របទេ ត្រូវធ្វើសេចក្ដីសម្រេចថាតើចំណាត់ប្រភេទអ្វីទើបសមស្រប"។

4. ផ្អែកតាមទឡ្ហីករណ៍ខាងលើ ចៅក្រមជាតិ យល់ឃើញថា ការធ្វើចំណាត់ថ្នាក់ឯកសារ "សម្ងាត់" ទៅជា "សាធារណៈ" នៅពេលនេះ គឺពុំទាន់មានភាពចាំបាច់ ហើយក៏មិននាំឱ្យប៉ះពាល់សិទ្ធិ និងផលប្រយោជន៍របស់ [redacted] ដែរ ព្រោះទោះបីឯកសារនោះជាប្រភេទ "ឯកសារសម្ងាត់" ក៏គាត់អាចមើលឯកសារទាំងនោះបានដែរ។ ហេតុដូចនេះ អង្គបុរេជំនុំជម្រះ គប្បីពិចារណាលើការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ នៅពេលចេញដីកាដំណោះស្រាយ និងសេចក្ដីសម្រេចប្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ អនុលោមតាមមាត្រា ៣.១២ វាក្យខណ្ឌទី២ នៃសេចក្ដីណែនាំអនុវត្ត អ.វ.ត.ក។

01241282



5. សហមេធាវីការពារក្តីលោក [redacted] បានធ្វើការអះអាងថា គោលការណ៍នីត្យានុកូលភាព ដែលត្រូវបានហៅផងដែរថា គោលការណ៍ គ្មានបទល្មើសបើគ្មានច្បាប់ចែង (nullum crimen sine lege) ហាមឃាត់ការធ្វើប្រតិសកម្មឧក្រិដ្ឋកម្ម ហើយតម្រូវឱ្យអំពើដែលបានហាមឃាត់ ត្រូវមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ ដើម្បីគ្រប់គ្រងអាកប្បកិរិយារបស់ប្រជាជន។ តាម គោលការណ៍នេះ ច្បាប់ត្រូវតែបកស្រាយដោយតឹងរ៉ឹង ហើយការពង្រីកសទិសភាពត្រូវបាន ហាមឃាត់។ តុលាការអាចបកស្រាយ និងបញ្ជាក់បំភ្លឺទៅលើច្បាប់ដែលមានជាធរមាន ប៉ុន្តែអង្គ សេចក្តីនៃច្បាប់ចាំបាច់ត្រូវតែអាចប្រមើរមើលបាន និងអាចដឹងឮបាន ដោយជនជាប់ចោទ នៅពេលប្រព្រឹត្តឧក្រិដ្ឋកម្មត្រូវបានចោទប្រកាន់[96]។

6. សហមេធាវីការពារក្តីលោក [redacted] បានធ្វើលើកទឡ្ហីករណ៍ថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក តម្រូវឱ្យតុលាការនេះ គោរពតាមគោលការណ៍នីត្យានុកូលភាព។ មាត្រា ៣៣ថ្មី នៃច្បាប់ ស្តីពីការបង្កើត អ.វ.ត.ក ចែងនៅក្នុងផ្នែកពាក់ព័ន្ធថា៖ អ.វ.ត.ក "ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន ស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ដូចដែលមាន ចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិការអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានតាក់តែង និងកំណត់ពីគោលការណ៍នីត្យានុកូលភាពថា[97]៖

"គ្មានបុគ្គលណាម្នាក់ត្រូវសម្រេចថាមានពិរុទ្ធភាពចំពោះបទល្មើសព្រហ្មទណ្ឌ ដោយផ្អែកលើ អំពើសកម្ម ឬអកម្មណាមួយ ដែលមិនបង្កើតបានជាបទល្មើសព្រហ្មទណ្ឌ តាមច្បាប់ជាតិ ឬអន្តរជាតិ នៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្ត។"

7. សហមេធាវីការពារក្តីលោក [redacted] បានធ្វើការបញ្ជាក់ថា គោលការណ៍នីត្យានុកូលភាព ត្រូវអនុវត្ត យ៉ាងតឹងរ៉ឹងជាពិសេស នៅក្នុងយុត្តាធិការប្រព័ន្ធច្បាប់ស៊ីវិល។ អង្គជំនុំជម្រះតុលាការ កំពូលរបស់ អ.វ.ត.ក បានពន្យល់ថា នីត្យានុកូលភាពគួរតែមាន "មុខងាររារាំង" (restraining function) នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ "រារាំងតុលាការ និងអង្គជំនុំជម្រះអន្តរជាតិ ឬ កូនកាត់ ពីការអនុវត្តន៍ជាឯកតោភាគីហួសពីយុត្តាធិការរបស់ពួកគេដោយមានការចែងយ៉ាងច្បាស់

---

[96] សំណើរបស់ [redacted] សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេត ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥, កថាខណ្ឌ ២១, ឯកសារ A259។

[97] ដូចយោងខាងលើ កថាខណ្ឌ ២២។

លាស់ពីកម្រិតកំណត់នៃអ្វីដែលជាអំពើព្រហ្មទណ្ឌ"។ ដោយសារធ្វើដូច្នេះ នីត្យានុកូលភាពការពារបុគ្គលពីការប្រើអំណាចតាមអំពើចិត្តរបស់រដ្ឋាភិបាល ក្រុមភាគច្រើន និងធានាសិទ្ធិជ្រុលហួសហេតុរបស់តុលាការ ព្រមទាំងធានាថា ពួកគេបានដឹងជាមុនពីអំពើអ្វីដែលត្រូវហាមឃាត់[98]។

8. សហមេធាវីការពារក្តីលោក [redacted] បានលើកឡើងថា រដ្ឋធម្មនុញ្ញ និងច្បាប់ព្រហ្មទណ្ឌកម្ពុជាក៏តម្រូវឱ្យតុលាការគោរពគោលការណ៍នីត្យានុកូលភាពដែរ។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាតម្រូវឱ្យតុលាការការពារសិទ្ធិដែលទទួលស្គាល់នៅក្នុងលិខិតុបករណ៍សិទ្ធិមនុស្សសំខាន់ៗ។ មាត្រានេះចែងនៅត្រង់ផ្នែកពាក់ព័ន្ធថា៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិ មនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្សសិទ្ធិនារី និង សិទ្ធិកុមារ"[99]។

9. សហមេធាវីការពារក្តីលោក [redacted] បានលើកឡើងបន្ថែមថា មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់" ហើយជាផលវិបាក "ការជំនុំជម្រះត្រូវតែធ្វើឡើង [.....] ដោយអនុលោមតាមនីតិវិធីច្បាប់ដែលនៅជាធរមាន"។ លើសពីនេះ មាត្រា ៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដែលជាច្បាប់មានសុពលភាពក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ តម្រូវមានការអនុវត្តដោយតឹងរ៉ឹងលើគោលការណ៍នីត្យានុកូលភាព ហាមអានុភាពប្រតិសកម្មនៃច្បាប់[100]។ ជាចុងក្រោយ សារៈសំខាន់នៃគោលការណ៍នីត្យានុកូលភាព មិនគ្រាន់តែត្រូវបានទទួលស្គាល់ និងសង្កត់ធ្ងន់ដោយច្បាប់បង្កើត អ.វ.ត.ក និងច្បាប់កម្ពុជានោះទេ ប៉ុន្តែគោលការណ៍នេះក៏ត្រូវបានទទួលស្គាល់ដោយតុលាការ អង្គជំនុំជម្រះ និងអ្នកសិក្សាស្រាវជ្រាវថ្នាក់ជាតិ តំបន់ និងអន្តរជាតិ[101]។

10. វិធាន ៧៦ (២) នៃវិធានផ្ទៃក្នុងកំណត់ថា "ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ នៅពេលដែលភាគីទាំងឡាយយល់ឃើញថា មានផ្នែកណាមួយត្រូវបានចាត់ទុកជាមោឃៈ ភាគីនោះអាចដាក់ពាក្យសុំ

---

[98] ដូចយោងខាងលើ កថាខណ្ឌ ២៣។

[99] ដូចយោងខាងលើ កថាខណ្ឌ ២៤។

[100] ដូចយោងខាងលើ កថាខណ្ឌ ២៥។

[101] ដូចយោងខាងលើ កថាខណ្ឌ ២៦។

ដោយបញ្ជាក់មូលហេតុទៅសហចៅក្រមស៊ើបអង្កេត ដើម្បីស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតប្ដឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាព។ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដែលអាចជាការទទួលយក ឬបដិសេធសំណើសុំភ្លាមៗតាមតែអាចធ្វើទៅបាន និងក្នុងគ្រប់ករណីទាំងអស់ត្រូវធ្វើឡើងមុនពេលចេញដីកាដំណោះស្រាយ។ រីឯវិធាន ៤៨ នៃវិធានផ្ទៃក្នុង ចែងថា "កិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធានបញ្ញត្តិ ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ។

11. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា អ.វ.ត.ក ត្រូវបានបង្កើតឡើងតាម កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (កិច្ចព្រមព្រៀង), ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ច្បាប់ អ.វ.ត.ក) និងអនុវត្តវិធានផ្ទៃក្នុង។

12. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាតុលាការពិសេសមួយដែលអនុវត្តនីតិវិធីនៃការចោទប្រកាន់ និងការស៊ើបសួរ ខុសពីតុលាការថ្នាក់ជាតិនៃប្រទេសកម្ពុជា។ ការចោទប្រកាន់ និងការស៊ើបសួររបស់តុលាការថ្នាក់ជាតិនៃប្រទេសកម្ពុជា គឺធ្វើឡើងតែលើអង្គហេតុទេ មាន ន័យថាមិនមែនជាការចោទប្រកាន់ និងការស៊ើបសួរលើបុគ្គលឡើយ[102]។ ផ្ទុយមកវិញនៅអង្គ ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការចោទប្រកាន់ និងការស៊ើបសួរ អាចធ្វើទៅបាន លុះត្រាបំពេញលក្ខខណ្ឌពីរ គឺ ទី១.***អង្គហេតុ*** "ឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩" និង ទី២.***បុគ្គល*** "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"[103]។

---

[102] មាត្រា ៤៤ និង ១២៥ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[103] មាត្រា ១ នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, មាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាល

13. ហេតុដូច្នេះចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណា ថាតើកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ បំពានទូវលក្ខខណ្ឌដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទី១២ ដែលនាំឲ្យមិនគោរពវិធានបញ្ញត្តិនៃការស៊ើបសួរដូចដែលបានពន្យល់នៅក្នុងកថាខណ្ឌ ១០ខាងលើ ជាហេតុធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ អោ អាន និងនាំឲ្យមោឃៈ ដែរ ឬទេ។

14. សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានខ្វែងយោបល់គ្នាចំពោះការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក្នុងសំណុំរឿង ០០៤ នេះ ដោយសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី ៣។ រីឯសហព្រះរាជអាជ្ញាជាតិបានបដិសេធចោលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី ៣ ផ្អែកលើមូលដ្ឋាន "ជនសង្ស័យទាំងនេះ មិនមែនជាមេដឹកនាំជាន់ខ្ពស់ និង/ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុត"[104] ហើយចៅក្រមជាតិ និងអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ក៏បានខ្វែងយោបល់គ្នាចំពោះបញ្ហានេះដែរ ដោយចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ គាំទ្រទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាជាតិ[105]។

15. តាមការយល់ឃើញខាងលើចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអាចស៊ើបសួរចំពោះ [redacted] លើអង្គហេតុនៃការរៀបការដោយបង្ខំបានទេ។

**ភ្នំពេញ ថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ២០១៦**

PRE-TRIAL CHAMBER • CHAMBRE PRÉLIMINAIRE • E.C.C.C. • C.E.T.C.

**ប្រាក់ គឹមសាន** **ន័យ ថុល** **ហួត វុទ្ធី**

---

កម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងវិធាន ៥៣ នៃវិធានផ្ទៃក្នុង។

[104] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំឲ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៩ និងសេចក្តីសង្ខេបរបស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០៩ កថាខណ្ឌទី ៨៦ (ក)។

[105] យោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ចុះថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០០៩ "[redacted] [redacted] មិនមែនជា មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"។

# មតិយោបល់លើអង្គសេចក្តីនៃសំណើ

## របស់ចៅក្រម Kang Jin BAIK និង ចៅក្រម Olivier BEAUVALLET

1. [redacted] លើកជាទឡ្ហីករណ៍ថា ការរំលោភលើសិទ្ធិនីត្យានុកូលភាពរបស់គាត់ អនុលោមតាមមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយសារការស៊ើបអង្កេតលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បង្កប់លក្ខណៈសម្បត្តិជាកំហុសនីតិវិធីដែលបង្កការខូចខាតលើផលប្រយោជន៍របស់គាត់ ដូច្នេះ វាតម្រូវឲ្យមោឃភាពកិច្ចដំណើរការនីតិវិធី។ ទោះបីជា [redacted] ពុំចង្អុលបង្ហាញ យោងលើឯកសារជាក់លាក់ណាមួយនៅក្នុងសំណុំរឿងក៏ដោយ ក៏ចៅក្រមដែលចុះហត្ថលេខាខាងក្រោមយល់ស្របថា មាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺជាវិធានដែលមានលក្ខណៈសំខាន់មានគោលបំណងធានានូវសិទ្ធិនីត្យានុកូលភាពរបស់បុគ្គលទាំងឡាយដែលបង្ហាញខ្លួននៅចំពោះ មុខ អ.វ.ត.ក។ អនុលោមតាមមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិនេះ គ្មានបុគ្គលណាម្នាក់ត្រូវសម្រេចថាមានពិរុទ្ធភាពលើបទល្មើសព្រហ្មទណ្ឌដោយសារអំពើសកម្ម ឬអំពើអកម្មរបស់ខ្លួនដែលពុំមែនជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់ជាតិ ឬអន្តរជាតិនៅក្នុងពេលប្រព្រឹត្តអំពើនោះទេ។ ដោយសារលក្ខណៈសំខាន់នៃសិទ្ធិនីត្យានុកូលភាព អង្គបុរេជំនុំជម្រះបានបង្ហាញជំហរស្របគ្នាថា ដើម្បីធានាឲ្យបាននូវសិទ្ធិនេះ បើទោះជាមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ក៏ដោយ អំពើព្រហ្មទណ្ឌ ឬទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក ត្រូវតែមានអត្ថិភាពនៅក្នុងច្បាប់នៅក្នុងអំឡុងពេលយុត្តាធិការនៃ អ.វ.ត.ក[106]។ តាមលក្ខខណ្ឌតម្រូវនៃមាត្រា ១២ នៅក្នុងកិច្ចព្រមព្រៀង ចៅក្រមដែលចុះហត្ថលេខាខាងក្រោមកត់សម្គាល់ឃើញថា បទដ្ឋានដូចមានចែងនៅក្នុងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មានអានុភាពជាប់ទាក់ទងដោយផ្ទាល់នឹង*ការអនុវត្ត* នៃយុត្តាធិការរបស់ អ.វ.ត.ក[107]។ ចំពោះការអនុវត្ត

---

[106] សាលដីកាលើសំណុំរឿង ០០២/អ.ប.ជ ៧៥ កថាខណ្ឌ ២១០, ២២៦, ២៤០, ៣២១-៣២៧, ៣៤១-៣៥១, ៣៦៦។

[107] មាត្រា ១២ នៃកិច្ចព្រមព្រៀងចែងថា៖ "អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ"។

យុត្តាធិការ អង្គបុរេជំនុំជម្រះបានសម្រេចថា តុលាការមានកាតព្វកិច្ចបញ្ជាក់ឱ្យបានច្បាស់ថាតើតុលាការមានយុត្តាធិការដែរ ឬទេនៅពេលខ្លួនទទួលបានរឿងក្តី[108]។ ម្យ៉ាងវិញទៀត អង្គបុរេជំនុំជម្រះបានសម្រេចថា ការជំទាស់នឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលសម្រេចតម្កល់ ទោះដោយប្រយោល[109] ឬ ដោយផ្ទាល់ក្តី[110] លើយុត្តាធិការរបស់ អ.វ.ត.ក អាចប្តឹងនៅក្នុងដំណាក់កាលមុនអង្គសេចក្តីនៅក្នុងកិច្ចដំណើរការនីតិវិធីបាន ហើយវាបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង[111]។

2. ចៅក្រមដែលចុះហត្ថលេខាខាងក្រោមកត់សម្គាល់ឃើញថា នៅក្នុងរឿងក្តីបច្ចុប្បន្ន [redacted] ពុំជំទាស់ដីកាសម្រេចណាមួយរបស់ ក.ស.ច.ស សម្រេចតម្កល់យុត្តាធិការរបស់ អ.វ.ត.ក នោះទេ។ [redacted] ជំទាស់កិច្ចស៊ើបសួរដែលបានបំពេញដោយ ស.ច.ស.អ ក្រោយពេល ស.ព.អ ដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ [redacted] តវ៉ាថា កិច្ចស៊ើបសួរបែបនេះមានកំហុស ពីព្រោះថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម "គឺជាការព្យាយាមមិនស្របច្បាប់ក្នុងការពង្រីកយុត្តាធិការរបស់តុលាការ"[112]។

3. ជាការពិតណាស់ ការស៊ើបអង្កេតលើអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានស្នើសុំតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ ដីកានេះស្នើឡើងថា អង្គហេតុនានាដូចបានរៀបរាប់ខាងលើ បង្កើតបានជាឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តា

---

[108] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ D97/14/15 កថាខណ្ឌ ២២៖ "នៅក្នុងច្បាប់កម្ពុជា ក៏ដូចជានៅក្នុងច្បាប់បារាំង តុលាការត្រូវតែរកឱ្យឃើញថាតើតុលាការមានយុត្តាធិការពេលវេលា និងយុត្តាធិការដែនដីចំពោះអង្គហេតុនានាដែលលើកឡើងចំពោះមុខតុលាការព្រមទាំងយុត្តាធិការលើកម្មវត្ថុចំពោះបទល្មើសនានាដែលត្រូវបានចោទប្រកាន់ដែរឬទេ" ("សាលដីកាសហឧក្រិដ្ឋកម្មរួម")។

[109] ការតវ៉ាដូចដែលបានលើកឡើងតាមរយៈបណ្តឹងសាទុក្ខលើសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង ០០២ (សូមមើល សាលដីកាសហឧក្រិដ្ឋកម្ម កថាខណ្ឌ ២៤)។

[110] ការតវ៉ាដូចដែលបានលើកឡើងប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ (សូមមើល អ.ប.ជ ៧៥, អ.ប.ជ ១៤៥ និង អ.ប.ជ ១៤៦)។

[111] សាលដីកាសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២៣-២៤។

[112] ពាក្យសុំ កថាខណ្ឌ ៣៤។

ធិការរបស់តុលាការ រួមទាំង ប៉ុន្តែមិនកំណត់ត្រឹមតែ ៖ ក) មនុស្សឃាត និងទារុណកម្មក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ហើយ ខ) "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" (រួមទាំង "អំពើមនុស្សធម៌ផ្សេងទៀត")[113]។

4. ចៅក្រមដែលចុះហត្ថលេខាខាងក្រោមសង្កេតឃើញថា ស.ច.ស.អ បានជូនដំណឹង [redacted] ថា "មានភ័ស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាថា គាត់អាចជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬ ជាប្រព័ន្ធ ដែលសំដៅលើប្រជាជនស៊ីវិលដោយមូលហេតុសញ្ជាតិ នយោបាយ ជាតិពិន្ទុ ពូជសាសន៍ ឬ សាសនា" ហើយ "គាត់ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋ៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ឬ សាសនា និង ការដាក់ក្នុងមន្ទីរឃុំឃាំង និង*អំពើអមនុស្សធម៌ផ្សេងទៀត (ដូចជា ស្ថានភាពអមនុស្សធម៌នៃការឃុំឃាំង)*[114]។

5. ស.ច.ស.អ ក៏បានផ្តល់យោបល់ជូន [redacted] ថា ស.ច.ស.អ "មុនពេលបញ្ចប់កិច្ចស៊ើបសួរ ស.ច.ស.អ អាចសម្រេចដាក់គាត់ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋបន្ថែមទៀតដោយផ្អែកតាមការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ*ស៊ើបសួរបន្ថែមលើកទី១ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី២* ប្រសិនបើ ស.ច.ស.អ ជឿជាក់ថា មានភ័ស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា [redacted] អាចជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋបែបនេះ"[115]។ នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ស.ច.ស.អ បានចោទប្រកាន់ [redacted] ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា អំពើអមនុស្សធម៌ផ្សេងៗទៀត រួមទាំងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាលើផ្លូវភេទជាក្រុមនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ តំបន់ ៤១[116]។

---

[113] ឯកសារ D191 កថាខណ្ឌ ១៣។

[114] ឯកសារ D242 ទំព័រ ៧។

[115] ឯកសារ D242 ទំព័រ ៨។

[116] កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀត ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ D303 ទំព័រ ១២ កថាខណ្ឌ ១២។

6. តាមប្រវត្តិនៃការស៊ើបអង្កេតកន្លងមក វាបង្ហាញយ៉ាងច្បាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងបំពេញកិច្ចតាមការចោទប្រកាន់ និងការលើកឡើងរបស់ ស.ព.អ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ពាក់ព័ន្ធនឹងយុត្តាធិការ សហចៅក្រមស៊ើបអង្កេតពុំមានឆន្ទានុសិទ្ធិអនុវត្តយុត្តាធិការនោះទេ[117]។ ប្រសិនបើ ស.ច.ស.អ បានរកឃើញថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមានកំហុសលើការចោទប្រកាន់ចំពោះអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក.ស.ច.ស ប្រាកដជាបានប្រកាសថាខ្លួនគ្មានយុត្តាធិការ ឬដូចអង្គបុរេជំនុំជម្រះបានសម្រេចរួចហើយថា[118] ក.ស.ច.ស ប្រាកដជាបានដាក់ពាក្យសុំ អនុលោមតាមវិធាន ៧៦(១) នៃវិធានផ្ទៃក្នុងយ៉ាងហោចណាស់សុំមោឃភាពផ្នែកខ្លះនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមបាត់ទៅហើយ។ ផ្ទុយមកវិញ ស.ច.ស.អ បានបំពេញកិច្ចស៊ើបសួរ ហើយក្នុងពេលបច្ចុប្បន្នបានប្ដឹង ពាក្យសុំរបស់ [redacted] ទៅអង្គបុរេជំនុំជម្រះទៅវិញ ហើយនាពេលថ្មីៗនេះ នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ បានចោទប្រកាន់ [redacted] ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា អំពើអមនុស្សធម៌ផ្សេងៗទៀត រួមទាំងអាពាហ៍ពិពាហ៍ដោយបង្ខំ។

7. ចៅក្រមដែលចុះហត្ថលេខាខាងក្រោមពិចារណាឃើញថា ទោះបីជាមោឃភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទងនឹងការចោទប្រកាន់លើ អំពើនៃការរៀបការដោយបង្ខំពុំមែនជាផ្នែកមួយនៃដំណោះស្រាយដែលបានស្នើសុំនៅក្នុងពាក្យសុំក៏ដោយ ក៏ការធ្វើមោឃ ភាពត្រូវបានស្នើសុំដោយប្រយោលនៅក្នុងនោះក្រោយពីបានពិនិត្យមើលសេចក្ដីថ្លែងការណ៍ នៅក្នុងពាក្យសុំនោះដែលថា "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមគឺជាការព្យាយាមមិនស្របច្បាប់ក្នុងការពង្រីកយុត្តាធិការរបស់តុលាការ" ហើយតាមរយៈសំណើសុំមោឃភាពកិច្ចស៊ើបសួរទាំងអស់នាពេលក្រោយមកផ្អែកតាមដីកានេះ។ ដូច្នេះ ក្រោយពីពិនិត្យមើលឡើងវិញលើមូលដ្ឋាននៃពាក្យសុំ ចៅក្រមដែលចុះហត្ថលេខាខាងក្រោមត្រូវពិនិត្យមើលនីយ័តភាព មិនមែនត្រឹមតែកិច្ច

---

[117] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៨០។

[118] សំណុំរឿង ០០៣ (អ.ប.ជ ២៦) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបានសម្រេចសាជាថ្មីលើញត្តិរបស់ [redacted] សុំ គូសចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ D120/3/1/8 កថាខណ្ឌ ៣១។

ស៊ើបសួរដែលបានធ្វើឡើងដោយឡែកនោះទេ ថែមទាំងលើកិច្ចស៊ើបសួរដែលបានធ្វើឡើងផ្អែកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមត្រង់ផ្នែកដែលពាក់ព័ន្ធផងដែរ។

8. នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ស.ព.អ ចោទប្រកាន់ថា អំពើនៃការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំបានកើតឡើង "នៅក្នុងបណ្តាស្រុក*ដែលស្ថិតនៅក្រោមការត្រួតត្រា ឬសិទ្ធិអំណាចរបស់ជនសង្ស័យក្នុងសំណុំរឿង ០០៤*"[119]។ ពាក់ព័ន្ធនឹង [redacted] យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ការរៀបការដូចបានចោទប្រកាន់ "*ពាក់ព័ន្ធនឹងគូស្រករជាច្រើនរហូតដល់ ៦០ គូ* ត្រូវបានបង្ខំឱ្យរៀបការនឹងគ្នាក្នុងពេលតែមួយ ហើយអាពាហ៍ពិពាហ៍ទាំងនេះត្រូវបាន*រៀបចំ និងដឹកនាំធ្វើដោយប្រធានអង្គភាព និងកម្មាភិបាល ប.ក.ក មូលដ្ឋានផ្សេងទៀត (ដែលពួកគេបានរាយការណ៍តាមឋានានុក្រមនៃខ្សែបញ្ជា ជូនទៅលេខាតំបន់)*។ [redacted] *គឺជាលេខាតំបន់* [...]"[120] ហើយ "ជនរងគ្រោះក្រោមអាពាហ៍ពិពាហ៍ដោយ បង្ខំនេះត្រូវបាន*តាមដាន*ដោយអ្នកឈ្លបយកការណ៍ ឬ កងឈ្លបដើម្បីធានាឱ្យប្រាកដថា *ពួកគេពិតជាបានរួមដំណេកជាមួយគ្នាដែលនេះ គឺជាកាលៈទេសៈដែលមានលក្ខណៈបង្ខិតបង្ខំជាប់មកជាមួយស្រេចដែលពួកកម្មាភិបាល ប.ក.ក បានបង្កើតឡើង និងដាក់ឱ្យអនុវត្ត*។ ប្រភពមកពីស្រុកនេះក៏បានបញ្ជាក់ផងដែរថា អ្នកទោសស្ត្រីត្រូវបានគេរំលោភសេពសន្ថវៈ មុននឹងត្រូវបានសម្លាប់ចោល"[121]។ ម្យ៉ាងវិញទៀត អំពើដូចបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម "គឺជា*ផ្នែកនៃផែនការឧក្រិដ្ឋកម្មរួម* ឬ សហឧក្រិដ្ឋកម្មរួមដូចបានរៀបរាប់ក្នុងកថាខណ្ឌ ២១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ និង កថាខណ្ឌ ១៦ ដល់ ១៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបី"[122]។ យោងតាម កថាខណ្ឌ ១៦ ដល់ កថាខណ្ឌ ១៧ នៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ "*ទិសដៅជាក់លាក់របស់សហឧក្រិដ្ឋកម្មរួមនេះគឺ កម្មាភិបាលមូលដ្ឋាន ក្រុមគ្រួសារ និង "ខ្សែបណ្តាញ" របស់អ្នកទាំងនោះ ព្រមទាំងប្រជាជនដែលមានទំនាក់ទំនងជាមួយ "សង្គមចាស់" ប្រជាជនថ្មី ឬ*

[119] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ១។

[120] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ២-៣។

[121] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ២។

[122] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ១៤។

*ប្រជាជន ១៩៧៥ ជនជាតិភាគតិចចាម និងអ្នកកាន់សាសនា និងអ្នកមានជាតិពន្ធុវៀតណាម*"[123]។ លើសពីនេះទៀត យោងតាមកថាខណ្ឌ ២១ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ "ផែនការឧក្រិដ្ឋកម្មរួមត្រូវបានគេ*អនុវត្តដោយបានដឹងជាមុន*ដោយមនុស្សជាច្រើន រួមទាំងលេខាស្រុករបស់ ប.ក.ក និងប្រធានមន្ទីរសន្តិសុខ ដែលម្នាក់ៗក៏ជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមស្ថិតនៅក្នុងស្រុក ឬ មន្ទីរសន្តិសុខរបស់ពួកខ្លួន។ បុគ្គលម្នាក់ៗទាំងនេះ តាមរយៈអំពើ និងការប្រព្រឹត្តិរបស់ខ្លួន បាន*រួមចំណែកធ្វើឱ្យសម្រេចបាននូវគោលដៅរួម*នៃសហឧក្រិដ្ឋកម្មរួម និង*ដែលមានចេតនាចង់បានលទ្ធផល*ទៅតាមនោះ"[124]។ ក្រោមចំណងជើង "ការកំណត់បទចោទ" នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ស.ព.អ លើកឡើងថា "សហព្រះរាជអាជ្ញាមានមូលហេតុដែលនាំឱ្យជឿបានថា អង្គហេតុនានាដូចបានរៀបរាប់ខាងលើរួមបង្កើតបានជាឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការ" រួមទាំង ប៉ុន្តែមិនកំណត់ត្រឹមតែឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ៖ "ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ឬ ពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត"[125]។

**មូលដ្ឋាន ក៖ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនមានអត្ថិភាពនៅក្នុងច្បាប់ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ នោះទេ**

9. អង្គបុរេជំនុំជម្រះ ក៏ដូចជាអង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា "អំពើអមនុស្សធម៌ផ្សេងទៀត" ត្រូវបានបង្កើតឡើងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅមុនឆ្នាំ ១៩៧៥[126]។ អំពើដែលចាត់ទុកជាបទឧក្រិដ្ឋនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" ពុំចាំ

---

[123] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១៦-១៧។

[124] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ (កាលបរិច្ឆេទចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១) ឯកសារ D65 កថាខណ្ឌ ២១។

[125] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ១៣។

[126] សំណុំរឿង ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ សាលក្រម ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ E188 ("សាលក្រមសំណុំរឿង ០០១") កថាខណ្ឌ ៣៦៧។ សាលដីកាសំណុំរឿង ០០២/អ.ប.ជ ៧៥ កថាខណ្ឌ ៣៧៩-៣៨៥, ៣៩៥-៣៩៦, ៣៩៨។ សាលដីកាសំណុំរឿង ០០២/អ.ប.ជ ១៤៥ និង ១៤៦ កថាខណ្ឌ ១៣០-១៣១, ១៥៧, ១៦៥។ សូមមើល

បាច់មានឋានៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយខ្លួនវានោះទេ។ អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថា "អំពើអមនុស្សធម៌ផ្សេងទៀត" គឺជាបទឧក្រិដ្ឋ នៅក្រោមច្បាប់អន្តរជាតិ ហើយអាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះពុំចាំបាច់បង្ហាញថា ប្រភេទអំពើនោះនីមួយៗនៅក្រោមប្រភេទអំពើអមនុស្សធម៌ផ្សេងទៀត ដែលត្រូវបានចោទប្រកាន់ថាស្ថិតនៅក្នុង វិសាល ភាពនៃបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ ត្រូវកំណត់ជាបទល្មើសព្រហ្ម ទណ្ឌនោះ ឡើយ[127]។ ផ្ទុយមកវិញ គោលការណ៍នីត្យានុកូលភាពភ្ជាប់ទំនាក់ទំនងជាមួយនឹងប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" ទាំងមូល ពុំមែនភ្ជាប់តែអំពើក្រោមអនុប្រភេទនៃអំពើអមនុស្សធម៌នេះឡើយ[128]។

10. អំពើផ្សេងទៀតដែលមិនឃើញមានចែងនៅក្នុងលិខិតុបករណ៍នានាគឺជាការរំលោភបំពានដ៏ទូលំទូលាយទៅលើសិទ្ធិជាមូលដ្ឋានរបស់បុគ្គល រួមទាំង សិទ្ធិទាក់ទងនឹងទ្រព្យសម្បត្តិ ការជំនុំជម្រះដោយយុត្តិធម៌ ការការពារសមភាពនៃច្បាប់ ភាពជាពលរដ្ឋ ការងារ ចំណេះដឹង *ការរៀបការ* ភាពឯកជន និងសេរីភាពដើរហើរ[129]។ ដូច្នេះ "ពុំមែនគ្រប់ការបដិសេធលើសិទ្ធិមនុស្សមានឃើញចែងកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរនោះឡើយ។ ផ្ទុយមកវិញ ទ្រឹស្តីនៃ*ប្រភេទអំពើដូចគ្នា*ត្រូវបានប្រើប្រាស់សម្រាប់បកស្រាយធម្មនុញ្ញរបស់សាលាក្តីដើម្បីកំណត់ "ឲ្យបានច្បាស់លាស់អំពីដែនកំណត់នៃប្រភេទអំពើនានា" ដែលជាការធានានូវកម្រិតជាក់លាក់ខ្លះរបស់វា[130]។ ចៅក្រមដែលចុះហត្ថលេខាខាងក្រោមយល់

---

ផងដែរ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stakić*, IT-97-24-A "សាលដីកា" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៣១៥។

[127] សាលដីកាសំណុំរឿង ០០២/អ.ប.ជ ៧៥ កថាខណ្ឌ ៣៧១, ៣៧៨។ សាលដីកាសំណុំរឿង ០០២/អ.ប.ជ ១៤៥ និង ១៤៦ កថាខណ្ឌ ១៥៦។

[128] សាលដីកាសំណុំរឿង ០០២/អ.ប.ជ ៧៥ ៣៧៨។

[129] សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ២៥៤។

[130] សាលដីកាសំណុំរឿង ០០២/អ.ប.ជ ៧៥ ៣៨៨-៣៨៩៖ "ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមទាំង ធម្មនុញ្ញតុលាការ Nuremberg ធម្មនុញ្ញទីក្រុងតូក្យូ ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និងគោលការណ៍ Nuremberg បានចែងនូវអំពើជាក់លាក់ដែលត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមបញ្ចូលទាំង "អំពើអមនុស្សធម៌ផ្សេងៗទៀត" ផងដែរ។ ពាក្យថា "ផ្សេងៗទៀត" ទាញចេញពី*គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយនូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* នៃវិធានក្នុងការបកស្រាយដែលក្នុងន័យនោះ "អំពើអនុស្សធម៌ផ្សេងៗទៀត" អាចត្រឹមតែរួមបញ្ចូលអំពើនានាដែលមានភាព "អមនុស្សធម៌" និងមាន "លក្ខណៈ និងស្ថានទម្ងន់ស្រដៀងគ្នា" ទៅនឹងអំពើដែលមានចែងជាក់លាក់ ពោលគឺ

ស្របថា វិធាននេះមានសារៈសំខាន់ ដោយហេតុថា វាអាចបំពេញមុខងារជាខប្បញ្ញត្តិសេសសល់នានាចែងគ្របដណ្តប់លើករណីនៃឥរិយាបទអមនុស្សធម៌ ដែលពុំចែងច្បាស់លាស់ថាស្ថិតនៅក្នុងប្រភេទដែលនៅសេសសល់ផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[131]។ ជាក់ស្តែង វាពុំចាំបាច់តម្រូវឱ្យពិនិត្យតាមដានមើលប្រវត្តិនៃការកំណត់បទល្មើសព្រហ្មទណ្ឌ លើអំពើជាក់លាក់នីមួយដោយហេតុថា "អំពើអមនុស្សធម៌ផ្សេងទៀត" មានអត្ថិភាពរួចហើយជាបទឧក្រិដ្ឋនៅក្នុងច្បាប់។ លក្ខខណ្ឌបន្ថែមមួយនៃការកំណត់បទល្មើស ព្រហ្មទណ្ឌលើអំពើក្រោមប្រភេទឥរិយាបទអមនុស្សធម៌នឹងធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរលើមុខងារដ៏សំខាន់នៃ "អំពើអមនុស្សធម៌ផ្សេងទៀត" ដែលជាបទឧក្រិដ្ឋ[132]។

---

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ និងការនិរទេស។ ៣៨៩. នៅក្នុងការសន្និដ្ឋានថា ទ្រឹស្តីនៃ *គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយនូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* មានភាពពាក់ព័ន្ធក្នុងការសម្រេចពីខ្លឹមសារនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" អង្គបុរេជំនុំជម្រះសង្កត់ធ្ងន់ថា វាមិនរំលោភដល់វិធានប្រឆាំងនឹងគោលការណ៍សទិសភាពដែលមាននៅក្នុងយុត្តាធិការផ្នែករប្បវេណីទេ។ ចំពោះ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ការយកបទល្មើសមួយតាមរយៈសទិសភាពមកអនុវត្តចំពោះការប្រព្រឹត្តដែលមិនមានចែងក្នុងច្បាប់ (*គោលការណ៍ analogia lexis*) ខុសប្លែកពីការយកប្រភេទរងមួយនៅក្នុងបទល្មើសមួយតាមរយៈសទិសភាពមកអនុវត្តចំពោះប្រភេទរងមួយទៀតនៅក្នុងបទល្មើសនោះក្នុងគោលបំណងបញ្ជាក់ឱ្យបានច្បាស់ពីនិយមន័យនៃប្រភេទរងមួយទៀតនោះ។ នៅក្នុងយន្តការទីពីរនេះ ប្រសិនបើការប្រព្រឹត្តដែលកំពុងពិភាក្សានោះស្ថិតទៅក្នុងនិយមន័យរបស់បទល្មើសនោះ ហេតុនេះការពិតវាជាការប្រព្រឹត្ត*ដែលមានចែងក្នុងច្បាប់* ហេតុនេះសំអាងហេតុនៃវិធានប្រឆាំងនឹងគោលការណ៍សទិសភាពមិនត្រូវយកមកអនុវត្តទេ។ ភាពខុសគ្នានេះមិនអាចចៀសវាងបានទេនៅពេលដែលត្រូវពិចារណាបន្ថែមទៀតថា ប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចែងជាក់លាក់ជាបទល្មើសមួយសេសសល់ដើម្បីបញ្ចៀសនូវភាពចន្លោះប្រហោងនៅក្នុងច្បាប់ ហើយថាពាក្យនេះមិនមានន័យទេប្រសិនបើមិនយក *គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយនូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* មកអនុវត្ត"។

[131] Antonio Cassese, Cassese's International Criminal Law, Third Edition, Oxford University Press, 2013 ("Cassese 2013"), ទំព័រ ៩៨។

[132] អង្គជំនុំជម្រះតុលាការកំពូលកបានផ្តល់គោលការណ៍ណែនាំខ្លះៗទាក់ទងនឹងវិធានការត្រូវអនុវត្តនៅក្នុងការពិនិត្យមើលថាតើអំពើជាក់លាក់ទាំងឡាយនោះអាចចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃបទឧក្រិដ្ឋដូចមានចែងដែរឬទេ។ នៅពេលសម្រេចលើមូលដ្ឋាននៃបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានបន្តបំពេញកិច្ចពិនិត្យ*តាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន* "ថាតើអំពើរំលោភសេពសន្ថវៈដូចបានកើតឡើងនៅ ស-២១ អាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃបទទារុណកម្មនៅក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ដែរឬទេ" (*សូមមើល* សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ១៨៤-២១០)។ វាបង្ហាញច្បាស់ថា នៅក្នុងពេលពិនិត្យបែបនេះ អង្គជំនុំជម្រះតុលាការកំពូលក្រោយពីបានរកឃើញថា ទារុណ

**មូលដ្ឋាន ខ៖ [redacted] មិនអាចប្រមើលមើល និងមិនដឹងច្បាប់នៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ដែលចែងថា អំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំអាចនាំឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។**

11. នៅក្នុងការព្យាយាមស្វែងរកនិយមន័យដែលមានអត្ថិភាពក្នុងច្បាប់នៅមុនឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ចំពោះពាក្យ "អំពើអមនុស្សធម៌ផ្សេងទៀត" អង្គបុរេជំនុំជម្រះបានសម្អាងលើបញ្ញើស្ដីពីប្រភពនានាដែលពន្យល់រៀបរាប់លម្អិតអំពីឫសគល់[133] និងការវិវឌ្ឍនានានៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរស្ដីពីនិយមន័យនោះ[134]។ និយមន័យទាំងអស់ចង្អុលបង្ហាញអំពីការយល់ជាទូទៅលើប្រភេទអ្វីខ្លះ[135]ដែលត្រូវបានហាមឃាត់នាពេលនោះ មានអត្ថិភាពនៅក្នុងអំឡុងពេលពាក់ព័ន្ធនឹងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

---

កម្មមានអត្ថិភាពជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចមានចែង និងក្រោយពេលកំណត់លើនិយមន័យនៅពេលនោះ ពុំបានបន្តទៅពិនិត្យថាតើអំពើរំលោភសេពសន្ថវៈដែលកំពុងប្ដឹងនៅចំពោះមុខនោះគឺជាបទឧក្រិដ្ឋកម្មឯកឯងដែរឬទេ។ ផ្ទុយមកវិញ អង្គជំនុំជម្រះតុលាការកំពូលបានបន្តធ្វើការប្រៀបធៀបសំអាងហេតុលើអំពើរំលោភសេពសន្ថវៈនោះជាមួយនឹងនិយមន័យនៃទារុណកម្មដោយសារវាមានចែងនៅក្នុងអំឡុងពេលស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

[133] សាលដីកាសំណុំរឿង ០០២/អ.ប.ជ ៧៥ កថាខណ្ឌ ៣៨៣៖ "និយមន័យនៃអំពើអមនុស្សធម៌ផ្សេងៗទៀតត្រូវបានចងក្រងតាមគោលការណ៍ VI(គ) នៃគោលការណ៍ Nuremberg គឺដកស្រង់ចេញពីបុព្វកថានៃសេចក្ដីប្រកាសនៅទីក្រុង St. Petersburg នៅឆ្នាំ១៨៦៨ និង Marterns Clause នៅក្នុងអនុសញ្ញាទីក្រុងឡាអេឆ្នាំ ១៨៩៩ និងឆ្នាំ ១៩០៧ ដែលបានអំពាវនាវឱ្យ "ប្រើប្រាស់ទំនៀមទម្លាប់ដែលបានបង្កើតឡើងដោយប្រជាជនដែលមានអារ្យធម៌ខ្ពង់ខ្ពស់ពីច្បាប់មនុស្សធម៌ និងការបង្គាប់បញ្ជានៃមនសិការសាធារណៈ" ជាការការពារបន្ទាប់បន្សំប្រឆាំងនឹងអំពើដែលមិនត្រូវបានហាមឃាត់ជាក់លាក់នៅក្នុងអត្ថបទនៃអនុសញ្ញាទីក្រុងឡាអេទេ។ ទោះបីគោលការណ៍ VI(គ) បានចែងពីអំពើជាក់លាក់ដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងនឹងច្បាប់មនុស្សជាតិក៏ដោយ តែគោលការណ៍បានចែងរៀបរាប់ជាច្រើនចំណុច និងបានរួមបញ្ចូលអំពើអមនុស្សធម៌ផ្សេងៗទៀត" ជាប្រភេទដែលនៅសេសសល់ដើម្បីបញ្ចៀសមិនឱ្យមានការផ្លាស់ប្ដូរច្បាប់មនុស្សធម៌ទេនៅក្នុងស្មារតីនៃ Marterns Clause។

[134] សាលដីកាសំណុំរឿង ០០២/អ.ប.ជ ៧៥ កថាខណ្ឌ ៣៨៥-៣៩៤។

[135] សាលដីកាសំណុំរឿង ០០២/អ.ប.ជ ៧៥ កថាខណ្ឌ ៣៩៥៖ "អាស្រ័យហេតុនេះ ដោយសារត្រឹមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មានចែងពីធាតុផ្សំ*រួម* និងធាតុផ្សំ*សត្យានុម័ត* អង្គបុរេជំនុំជម្រះយល់ឃើញថា បទល្មើសសកម្ម ឬ អកម្មមួយដែលរងការជំទាស់បានបង្កើតជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" មួយជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅពេលដែលអំពើនោះមាន*លក្ខណៈ និងស្ថានទម្ងន់ស្រដៀងគ្នា*ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ឬ ការនិរទេសដែល៖ ១) វាមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅនឹងជីវិត ឬ សេរីភាពរបស់មនុស្ស រួមមាន *ការធ្វើបាបដែលបណ្ដាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរដល់រាងកាយ និងផ្លូវចិត្តទៅលើមនុស្ស* ឬ ២) *មានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិណាមួយដែលបានរៀបរាប់*តាមវិធីផ្សេងទៀត។ នៅក្នុងទិដ្ឋភាពនេះ គេអាចប្រមើល

12. ចៅក្រមដែលចុះហត្ថលេខាខាងក្រោមសន្និដ្ឋានថា ទោះបីជាត្រឹមឆ្នាំ ១៩៧៥ ធាតុផ្សំទូទៅនៃអំពើអមនុស្សធម៌ផ្សេងទៀតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំមានចែងចង្អុលបញ្ជាក់ច្បាស់ លាស់ ឬពេញលេញស្របតាមការយល់ឃើញរបស់យើង អំពីធាតុផ្សំទាំងនេះនាពេល បច្ចុប្បន្នក៏ដោយ ក៏គោលការណ៍ដែលថា បុគ្គលម្នាក់អាចតម្រូវឱ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មដែល "មានលក្ខណៈ និងស្ថានទម្ងន់ប្រហាក់ប្រហែលគ្នា" នឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងទៀតដូចបានរៀបរាប់ក្នុងនោះ ត្រូវបានបង្កើតឡើង ហើយជនជាប់ចោទបានដឹងជារួម ថែមទាំងអាចប្រមើលមើល និងដឹងថាមានច្បាប់ចែងទៀត ផង[136]។

13. វាបង្ហាញច្បាស់ថា អំពើបង្ខំប្រជាជនឱ្យប្រព្រឹត្តអ្វីមួយផ្ទុយនឹងឆន្ទៈខ្លួនឯង ទោះក្នុងវិធីណាមួយក៏ដោយអាចស្ថិតនៅក្នុងនិយមន័យនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" តាមរយៈការចង្អុលបញ្ជាក់ច្បាស់លាស់ពីតុលាការ ដោយផ្អែកលើការប្រើប្រាស់ទ្រឹស្តីនៃ*ប្រភេទអំពើដូចគ្នា*ទៅតាមករណីនីមួយៗ[137]។ គោលការណ៍នីត្យានុកូលភាពពុំរារាំងតុលាការ មិនថានៅថ្នាក់ជាតិ ឬ អន្តរជាតិ មិនឱ្យសម្រេចបញ្ហាណាមួយតាមរយៈការបកស្រាយ និងការបញ្ជាក់បំភ្លឺលើធាតុផ្សំនៃបទឧក្រិដ្ឋជាក់លាក់មួយនោះទេ ឬ "លើអត្ថន័យសម្រាប់កំណត់ធាតុផ្សំជាក់លាក់ណាមួយនៃបទឧក្រិដ្ឋនោះឡើយ[138]។

---

មើលជាមុនថា អំពើនានាត្រូវបានហាមឃាត់ដោយបញ្ញត្តិអន្តរជាតិស្តីពីជម្លោះប្រដាប់អាវុធ*ដោយផ្អែកលើមូលដ្ឋានអមនុស្សធម៌ក៏នឹងត្រូវបានហាមឃាត់ស្រដៀងគ្នានេះដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត*។ និយមន័យនៃពាក្យថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ទំនងជាសំដៅដល់អំពើនានាដែលនឹងត្រូវចាត់ទុកជាការរំលោភធ្ងន់ធ្ងរ ឬ ការបំពារបំពានធ្ងន់ធ្ងរ*ដែលក្នុងចំណោមនោះ* មានបទប្បញ្ញត្តិទីក្រុងឡាអេឆ្នាំ១៨៩៩ បទប្បញ្ញត្តិទីក្រុងឡាអេឆ្នាំ ១៩០៧ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩២៩ និង អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដែលចែងថា អំពើទាំងនោះស្របទៅនឹងលក្ខខណ្ឌតម្រូវជាក់លាក់ដទៃទៀតនៅក្នុងលិខិតុបករណ៍ទាំងនេះ"។

[136] សាលដីកាសំណុំរឿង ០០២/អ.ប.ជ ៧៥ កថាខណ្ឌ ៣៩៦។

[137] សាលាក្តីក្រោយសង្គ្រាមលោកលើកទីពីរ បានប្រើប្រាស់ទ្រឹស្តីបែបនេះដើម្បីបញ្ជាក់បំភ្លឺច្បាប់ផងដែរ។ *សូមមើល* សាលដីកាសំណុំរឿង ០០២/អ.ប.ជ ៧៥ កថាខណ្ឌ ៣៨៨-៣៩០។

[138] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ៩៥៖ "ពេលដែលអង្គជំនុំជម្រះបានកំណត់ថា បទល្មើសដែលបានចោទប្រកាន់ ឬ ទម្រង់នៃការទទួលខុសត្រូវអត្ថិភាពនៅក្នុងច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិនៅពេលអំពើនោះជាបទល្មើស នោះគោលការណ៍នីត្យានុកូលភាពអន្តរជាតិមិនហាមឃាត់អង្គជំនុំជម្រះធ្វើការបកស្រាយ ឬ បំភ្លឺច្បាប់ ឬ ផ្អែកលើសេចក្តីសម្រេចទាំងនោះដែលនៅក្នុងរឿងក្តីដទៃទៀត ក៏បានធ្វើដូច្នេះដែរនោះទេ"។ *សូមមើលផងដែរ* កថាខណ្ឌ ១០០៖ "ការអនុវត្តយុត្តាធិការរបស់អង្គជំនុំ

14. ចៅក្រមដែលចុះហត្ថលេខាខាងក្រោមពុំយល់ឃើញថា ទឡ្ហីករណ៍របស់ [redacted] លើចំណុចនេះ ចាប់បង្ខំឱ្យងាកចេញពីយុត្តិសាស្ត្រទាំងនេះនោះទេ។

**មូលដ្ឋាន គ៖ បើទោះជា អ.វ.ត.ក បំពេញកិច្ចត្រឹមត្រូវ "ក្នុងការអនុម័តយកដោយប្រតិសកម្មចំពោះនិយមន័យនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ [...] អំពើបែបនេះមិនមាន "លក្ខណៈ និងស្ថានទម្ងន់ប្រហែលគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងដទៃទៀតឡើយ"។**

15. ធាតុផ្សំបទឧក្រិដ្ឋនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" រួមទាំងអំពើសកម្ម ឬ អំពើអកម្មរបស់ជនជាប់ចោទ ឬ បុគ្គលិកក្រោមបង្គាប់របស់ពួកគេ៖

(i) បង្កឱ្យមានការឈឺចាប់រាងកាយ ឬផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ឬប្រព្រឹត្តការវាយប្រហារដ៏ធ្ងន់ធ្ងរមួយទៅលើសេចក្តីថ្លៃថ្នូរជាមនុស្សជាតិ និង

(ii) មានចេតនាបង្កឱ្យមានការឈឺចាប់រាងកាយ ឬផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ឬបង្កើតបានជាការវាយប្រហារដ៏ធ្ងន់ធ្ងរមួយទៅលើសេចក្តីថ្លៃថ្នូរជាមនុស្សជាតិរបស់ជនរងគ្រោះនៅពេលប្រព្រឹត្តអំពើសកម្ម ឬអំពើអកម្មនោះ[139]។

អំពើសកម្ម ឬអំពើអកម្មត្រូវមានលក្ខណៈ និងស្ថានទម្ងន់ស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតដែលមានចែងកំណត់[140]។

16. [redacted] សន្និដ្ឋានថា ដើម្បីឱ្យអំពើជាក់លាក់មួយមានលក្ខណៈ និងស្ថានទម្ងន់ប្រហាក់ប្រហែលគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងទៀតដែលមានការកំណត់ត្រឹមត្រូវ, អំពើជាក់លាក់នោះ *ត្រូវ*មានលក្ខណៈជាអំពើព្រហ្មទណ្ឌ ពីព្រោះ "ឧក្រិដ្ឋភាពគឺជាផ្នែកនៃលក្ខណៈជាសារវន្តនៃ

---

ជម្រះត្រូវបានកម្រិតដោយនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំង[...]ដូចដែលមានកំណត់តាមច្បាប់ [...] នៅពេលដែលអំពើល្មើសត្រូវបានចោទប្រកាន់បានប្រព្រឹត្តឡើង"។

[139] *សូមមើល* សាលក្រមសំណុំរឿង ០០១ កថាខណ្ឌ ៣៧១។ សាលដីកាសំណុំរឿង ០០២/អ.ប.ជ ៧៥ កថាខណ្ឌ ៣៩៥-៣៩៦។ សាលក្រមសំណុំរឿង ០០១ កថាខណ្ឌ ៤៣៧ *យោងលើ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Dragomir Milošević សំណុំរឿងលេខ IT-98-29/1-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១២ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ១០៨។

[140] សាលក្រមសំណុំរឿង ០០១ កថាខណ្ឌ ៣៦៧។ សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៤៣៨ *យោងលើ* សាលដីកាសំណុំរឿង ០០២/អ.ប.ជ ៧៥ កថាខណ្ឌ ៣៩៥-៣៩៦ *និងយោងលើ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krajišnik* សំណុំរឿងលេខ IT-00-39-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ៣៣១។

01241297



ឧក្រិដ្ឋកម្ម [ប្រឆាំងមនុស្សជាតិ]ដែលបានកំណត់"[141]។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ភាពធ្ងន់ធ្ងរនៃអំពើជាក់លាក់មួយត្រូវវាយតម្លៃទៅតាមករណីនីមួយៗ ដោយគោរពទៅតាមកាលៈទេសៈនៃករណីនីមួយៗ។ ករណីទាំងនេះអាចរួមទាំង "ប្រភេទនៃអំពើសកម្ម ឬអកម្ម បរិបទដែលវាបានកើតឡើង កាលៈទេសៈផ្ទាល់ខ្លួនរបស់ជនរងគ្រោះ រាប់បញ្ចូលទាំង អាយុ ភេទ និងសុខភាព ព្រមទាំងផលប៉ះពាល់ផ្នែកសីលធម៌ ផ្នែកផ្លូវកាយ និងផ្លូវចិត្តនៃអំពើនោះមកលើជនរងគ្រោះ"[142]។ ទោះបីជាឧក្រិដ្ឋភាពនៃអំពើជាក់លាក់ណាមួយ អាចចង្អុលបញ្ជាក់ទូទៅអំពីភាពធ្ងន់ធ្ងររបស់វាក៏ដោយ វាក៏ពុំមែនជាកត្តា*កំណត់ជាក់លាក់* ឬជាកត្តាតែមួយគត់ដែលត្រូវពិចារណានោះទេ។

17. ម្យ៉ាងវិញទៀត ដូចអង្គជំនុំជម្រះតុលាការកំពូលរបស់ អ.វ.ត.ក ធ្លាប់បានរំលឹករួចមកហើយថា ប្រវត្តិអំពើកន្លងមកមុនមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឃើញមានតាំងពីអំឡុងឆ្នាំ ១៨៦៨ ដល់ឆ្នាំ១៩០៧ ដោយបានយោងលើ "ការរំលោភ "*ច្បាប់មនុស្សធម៌*" និង "*ការរំលោភ* [...] *ច្បាប់ជាសារវន្តនៃមនុស្សធម៌*""[143]។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា "ការដាក់បញ្ចូលគ្នានៃ "ច្បាប់ និងទំនៀមទម្លាប់សង្គ្រាម" និង "ច្បាប់មនុស្សជាតិ" សន្មតទុកជាមុនយ៉ាងច្បាស់ថា ឧក្រិដ្ឋកម្មនានា ដែលមានចែងយ៉ាងដូច្នេះកើតចេញពីការរំលោភបំពានលើ*របបគតិយុត្តពីរផ្សេងគ្នា*"[144]។ នៅពេលអាន*អត្ថបទដើម*របស់ចៅក្រមដែលចុះហត្ថលេខាខាងក្រោម ឃ្លា "អំពើអមនុស្សធម៌ផ្សេងទៀត" ដែលឃើញមានចែងនៅក្នុងមាត្រា ៦(គ) នៃធម្មនុញ្ញ នុ័រមប៊ឺក ពុំបានបញ្ចូលពាក្យ "ព្រហ្មទណ្ឌ" នោះទេ ប៉ុន្តែ វារួមមានពាក្យ "អមនុស្សធម៌"។ យោងតាមយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ នៅពេលសម្រេចលើបញ្ហានៃឧក្រិដ្ឋកម្មប្រឆាំងមនុស្ស

---

[141] ពាក្យសុំ កថាខណ្ឌ ៣២។

[142] សាលក្រមលើសំណុំរឿង ០០១ កថាខណ្ឌ ៣៦៩។ សូមមើលផងដែរ ពាក្យសុំ លេខយោងជើងទំព័រ ៧៥ និង ៧៦ *យោងលើរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kupreskic* និងអ្នកផ្សេងទៀត សំណុំរឿងលេខ IT-95-16-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ៥៦៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kayishema និង Ruzindana* សំណុំរឿងលេខ ICTR-95-1-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៥១ និង*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Vasiljevic* សំណុំរឿងលេខ IT-98-32-T សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ កថាខណ្ឌ ១៦៥។

[143] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១០២។

[144] សំណុំរឿង ០០១ សាលដីកា កថាខណ្ឌ ១០២។

ជាតិថាជាការរំលោភលើច្បាប់អន្តរជាតិ ចៅក្រមបានលើកឡើងថា "ជាសង្ខេប ការចោទប្រកាន់ទោសគឺសំដៅដល់ការចូលរួមផ្នែកមនសិការទៅក្នុងប្រព័ន្ធនៃអំពើសាហាវឃោរឃៅ និងអយុត្តិធម៌ ដែលមានរចនាសម្ព័ន្ធគ្រប់គ្រងទូទាំងប្រទេស ក្នុងការរំលោភដល់ច្បាប់ស្តីពីសង្គ្រាម *និងច្បាប់ស្តីពីមនុស្សធម៌*"[145]។

18. ចំណុចចុងក្រោយ ទាក់ទងនឹងទឡ្ហីករណ៍ដែលថា៖ i) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនអាចញែកឱ្យដាច់ពីគ្នាពីការរៀបអាពាហ៍ពិពាហ៍ក្រោមការរៀបចំ ហើយ ii) ទោះបីជាការរំលោភលើស្វ័យភាពរបស់បុគ្គល និងសិទ្ធិស្វ័យសម្រេចអាចមានផលប៉ះពាល់ក៏ដោយ ក៏ការខូចខាតដែលបានបណ្តាលមកពីការរំលោភបែបនេះពុំអាចប្រៀបបាននឹងការខូចខាត ដែលកើតចេញពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលមានចែងកំណត់ត្រឹមត្រូវនោះឡើយ។ ចៅក្រមដែលចុះហត្ថលេខាខាងក្រោមគូសបញ្ជាក់ឡើងថា ការប្រៀបធៀបទាំងនោះជាប់ទាក់ទងនឹងបញ្ហាអង្គច្បាប់ និងអង្គហេតុលាយឡំគ្នា[146]។ នៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធីនៅពេលស៊ើបដែលកិច្ចស៊ើបសួរកំពុងធ្វើឡើង វាជាការធ្វើឡើងមុនដំណាក់ការនីតិវិធីក្នុងការប្រៀបធៀបណាមួយ ពីព្រោះថា ការវាយតម្លៃថាតើអំពើដូចបានចោទប្រកាន់មានលក្ខណៈធ្ងន់ធ្ងរ ឬ មិនធ្ងន់ធ្ងរនោះ អាចធ្វើឡើងទៅបាន នៅពេលណាកាលៈទេសៈដែលត្រូវបានចោទប្រកាន់ដោយចង្អុលបញ្ជាក់លើភាពធ្ងន់ធ្ងរនោះ ត្រូវបង្ហាញឱ្យឃើញថាមានអត្ថិភាពជាមុនសិន។

---

145 សាលដីកាសំណុំរឿង ០០២/អ.ប.ជ ៧៥ កថាខណ្ឌ ៣៩២ យោងលើរឿងក្តី *Justice* ទំព័រ ៩៨៥។ សូមមើលផងដែរ សាលដីកាសំណុំរឿង ០០២/អ.ប.ជ ៧៥ កថាខណ្ឌ ៣៩៣-៣៩៤៖ "នៅក្នុងរឿងក្តី*គ្រពេឡ* ឧក្រិដ្ឋកម្មសង្គ្រាមស្តីពីការប្រព្រឹត្ត "ការពិសោធន៍វេជ្ជសាស្ត្រ" ដោយគ្មានការព្រមព្រៀងប្រឆាំងនឹងប្រជាជនដែលមិនមែនជាជនជាតិអាល្លឺម៉ង់ និងកងកម្លាំងប្រដាប់អាវុធ ក៏ត្រូវបានចោទប្រកាន់ និងរកឃើញពិរុទ្ធភាពផងដែរដើម្បីបង្កើតជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រឆាំងនឹងជនជាតិអាល្លឺម៉ង់។ ៣៩៤. នៅក្នុងរឿងក្តី*រដ្ឋមន្ត្រី* ចុងចោទត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសតាមបទចោទទី៥ ពីបទ៖ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលពួកគេបានចូលរួមក្នុងអំពើឃោរឃៅ និងបទល្មើស រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការសម្លាប់ចំណាប់ខ្មាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា និងអំពើអមនុស្សធម៌ និងអំពើឧក្រិដ្ឋផ្សេងៗទៀតប្រឆាំងនឹងជនជាតិអាល្លឺម៉ង់ និងសមាជិកនៃប្រជាជនស៊ីវិលនៃបណ្តាប្រទេស និងទឹកដីដែលស្ថិតក្រោមការកាន់កាប់បែបប្រទូស្តរ៉ាយ ឬ ដែលបានត្រួតត្រាតាមវិធីផ្សេងទៀតដោយប្រទេសអាល្លឺម៉ង់ [...]" ។

146 សាលដីកាសំណុំរឿង ០០២/អ.ប.ជ ៧៥ កថាខណ្ឌ ៣៩៧។

01241299



## VI. សេចក្តីសន្និដ្ឋាន

19. សរុបមក ចៅក្រមដែលចុះហត្ថលេខាខាងក្រោមពុំចាត់ទុកអង្គសេចក្តីនៅក្នុងទឡ្ហីករណ៍ណាមួយរបស់ [redacted] ដែលថា ការស៊ើបអង្កេតលើអំពើដែលរងការចោទប្រកាន់លើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមានកំហុសនោះទេ ពីព្រោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម "គឺជាការព្យាយាមមិនស្របច្បាប់ក្នុងការពង្រីកយុត្តាធិការរបស់តុលាការ"។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" ដូចដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[147] ស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ ក្រោយពីបានទទួលបណ្តឹងលើបទឧក្រិដ្ឋនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក, ក.ស.ច.ស មានកាតព្វកិច្ចតាមផ្លូវច្បាប់បំពេញកិច្ចស៊ើបសួរ[148] ដើម្បី "បញ្ជាក់ការពិត"[149]។ ការស៊ើបអង្កេតដែលកំពុងបន្តធ្វើឡើងលើអំពើនានាដូចដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពុំរំលោភសិទ្ធិនីត្យានុកូលភាពរបស់ [redacted] អនុលោមតាមមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនោះទេ ហេតុដូច្នេះ វាគ្មានកំហុសនីតិវិធីណាមួយដែលបង្កការខូចខាតលើផលប្រយោជន៍របស់គាត់ដែលតម្រូវឱ្យមោឃភាពកិច្ចដំណើរការនីតិវិធីបែបនេះឡើយ។

**រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ២០១៦**

**Olivier BEAUVALLET** **Kang Jin BAIK**

[147] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ១៣៖ "សហព្រះរាជអាជ្ញាមានមូលហេតុនាំឱ្យជឿបានថា អង្គហេតុនានាដូចបានរៀបរាប់ខាងលើរួមបង្កើតបានជាឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការ" រួមមាន ប៉ុន្តែមិនកំណត់ត្រឹម*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ* "ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ឬ ពូជសាសន៍ និង*អំពើអមនុស្សធម៌ផ្សេងទៀត*"។

[148] វិធាន ៥៥(១) នៃវិធានផ្ទៃក្នុងចែងថា៖ "ការស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"។

[149] វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង។